**កំណត់ហេតុ**

**សន្និសីទថ្នាក់ជាតិដើម្បីចាប់ផ្ដើមជាផ្លូវការនូវយន្តការ ខប់សែល* ដំណាក់កាលទី ២**

រៀបចំដោយ មជ្ឈមណ្ឌលដើម្បីសន្តិភាព និង អភិវឌ្ឍន៍

នៃវិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

ថ្ងៃទី១៤ កក្កដា ២០០៥ នៅសណ្ឋាគារភ្នំពេញ

## ១. សេចក្ដីផ្ដើម

សន្និសីទថ្នាក់ជាតិដើម្បីចាប់ផ្ដើមជាផ្លូវការនូវយន្តការខប់សែលដំណាក់កាលទី ២ បានប្រារព្ធធ្វើនៅថ្ងៃទី១៤ កក្កដា ២០០៥ ចាប់ពីម៉ោង ៧:៣០នាទី ដល់ម៉ោង ១២:៣០នាទី នៅសណ្ឋាគារភ្នំពេញ ដោយមានការចូលរួមជាអធិបតីក្នុងពិធីបើកដោយឯកឧត្តម **អ៊ឹម សួស្ដី** ប្រធានគណៈកម្មាការជាតិរៀបចំការបោះឆ្នោត លោក **Larry Strange** នាយកប្រតិបត្តិវិទ្យាស្ថាន វបសអ និងអ្នកស្រី **Anne-Issabelle Degryse-Blateau** ប្រធានកម្មវិធី និងតំណាង UNDP ។ សន្និសីទនេះបិទដោយឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ តំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ក្នុងសន្និសីទនេះមានវាគ្មិនចំនួន ៨រូប ចូលរួមផ្ដល់បទឧទ្ទេសនាមលើប្រធានបទ *"ទំនាស់ដែលអាចកើតមានក្នុងដំណើរការបោះឆ្នោតទាំងបីខាងមុខនៅកម្ពុជា និងនីតិវិធីជាយុទ្ធសាស្ត្រដើម្បីដោះស្រាយ"* ។ វាគ្មិនទាំង ៨រូបនោះរួមមាន: (១) ឯកឧត្តម **ប៉ែន បញ្ញា** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មការកណ្ដាលនៃគណបក្សប្រជាជនកម្ពុជា និងប្រធានគណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្ដឹងនៃរដ្ឋសភា, (២) ឯកឧត្តម **ទា ចំរ៉ាត់** អគ្គលេខាធិការរងគណបក្សហ៊្វុនស៊ិនប៉ិច អនុប្រធានគណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាតនៃព្រឹទ្ធសភា, (៣) ឯកឧត្តម **ទេព នីថា** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (៤) លោក **គុល បញ្ញា** នាយកប្រតិបត្តិនៃគណៈកម្មាធិការខុមហ្វ្រែល, (៥) លោកជំទាវ **ប៉ុក ណណ្ដា** នាយកប្រតិបត្តិនៃអង្គការចំរើនស្ត្រី, (៦) លោក **ឡា ដារ៉ុឡ** ទីប្រឹក្សាគណបក្ស សម រង្ស៊ី, (៧) ឧត្តមសេនីយ៍ត្រី **សារ៉ាន កំសត់** ប្រធានមន្ទីរចាត់ការនៃសាលាភូមិន្ទនគរបាលនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ, និង (៨) លោកបណ្ឌិត **ហង្ស ពុទ្ធា** នាយកប្រតិបត្តិនៃអង្គការនិកហ្វិច ។

សន្និសីទនេះមានការចូលរួមយ៉ាងទូលំទូលាយពីសំណាក់ភាគីពាក់ព័ន្ធក្នុងការបោះឆ្នោត ដែលមានតំណាងមកពី រាជរដ្ឋាភិបាលកម្ពុជា គណបក្សនយោបាយ (គណបក្សប្រជាជនកម្ពុជា, គណបក្សហ៊្វុនស៊ិនប៉ិច, គណបក្សសម រង្ស៊ី, និងគណបក្សប្រជាធិបតេយ្យខ្មែរ) គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត, ព្រឹទ្ធសភា, រដ្ឋសភាជាតិ, អភិបាលនិងអភិបាលរងគ្រប់ខេត្ត-ក្រុង, សមាជិកក្រុមប្រឹក្សាឃុំសង្កាត់, អង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ, សង្គមស៊ីវិល, សហគមន៍អ្នកផ្ដល់ជំនួយ, ស្ថានទូតបរទេស, និងបណ្ដាញសារពត៌មានជាតិ និងអន្តរជាតិ សរុបទាំងអស់មានចំនួន ២២៥នាក់ ។

## ២. កំណត់ហេតុសង្ខេប

ជាកិច្ចចាប់ផ្ដើម លោក **ឱក សេរីសោភក្ដិ៍** អ្នកសំរបសំរួលយន្តការខប់សែល បានសំដែងនូវគារវកិច្ច និងអំណរគុណចំពោះគណៈអធិបតីភ្ញៀវជាតិ និងអន្តរជាតិដែលមានវត្តមានក្នុងអង្គសន្និសីទ ។ លោកបានទាក់ទាញអារម្មណ៍របស់អង្គសន្និសីទដោយការរំលឹកយ៉ាងខ្លីទៅដល់ខប់សែលដំណាក់កាលទី ១ ដែលបានរៀបចំកិច្ចប្រជុំប្រចាំខែចំនួន ៥០លើក ដោយមិនដែលអាក់ខានរវាងពីខែសីហា ១៩៩៩ រហូតដល់ខែកញ្ញា ២០០៣ ។ លោកបានគូសបញ្ជាក់ថា ដោយមើលឃើញពីប្រសិទ្ធិភាព និងគុណប្រយោជន៍នៃយន្តការខប់សែល ទើប UNDP និង CDRI សុំអោយរូបលោកដែលជាអ្នកផ្ដួចផ្ដើមយន្តការនេះក្នុងក្របខ័ណ្ឌ CDRI បន្តបំពេញតួនាទីជាអ្នកសំរបសំរួលខប់សែលដំណាក់កាលទី ២ ក្នុងរយៈពេលបីឆ្នាំខាងមុខតទៅទៀត ។ ក្នុងនាមលោកជាអ្នកផ្ដួចផ្ដើម និងអ្នកសំរបសំរួលយន្តការនេះ លោកបានសំដែងអំណរគុណយ៉ាង

ជ្រាលជ្រៅដល់ UNDP ចំពោះការមានចក្ខុវិស័យទូលំទូលាយអំពីខប់សែល និងចំពោះបំណងប្រើប្រាស់យន្តការនេះក្នុងវិស័យផ្សេងៗទៀត ដែលមានជំលោះចំរូងចំរាស់ ។ លោកក៏ថ្លែងអំណរគុណដល់ AusAID ចំពោះបំណងចង់ផ្តល់ជំនួយហិរញ្ញវត្ថុដល់យន្តការនេះ ។

បន្ថែមលើឯកសារខប់សែលដែលបានចែកជូនអង្គសន្និសីទ លោក **ឱក សេរី សោភក្តិ៍** បានបញ្ជាក់បន្ថែមថា ខប់សែលដំណាក់ទី ២ រួមមាន ៦រចនាសម្ព័ន្ធ ហើយបើទោះបីខប់សែលប្រជុំស្នូលពាក់ព័ន្ធតែជាមួយអ្នកជំនាញខាងការងារបោះឆ្នោតមួយក្រុមតូចមែន តែយើងក៏យកចិត្តទុកដាក់ដល់តួអង្គដទៃៗទៀតផងដែរ ដោយការរៀបចំអោយមានខប់សែលប្រជុំទូលាយ និងខប់សែលប្រជុំថ្នាក់ខេត្តក្រុង ។ លោកបានឆ្លៀតឱកាសថ្លែងអំណរគុណដល់ឯកឧត្តមអភិបាល និងអភិបាលរងខេត្ត-ក្រុង ដែលមានវត្តមានក្នុងសន្និសីទដែលបានជួយជ្រោមជ្រែង និងសហការជារៀងរហូតជាមួយយន្តការខប់សែល ហើយក្នុងរយៈពេលបីឆ្នាំខាងមុខ នឹងមានកិច្ចប្រជុំខប់សែលចំនួន ៤៦លើក នៅតាមបណ្តាខេត្ត-ក្រុងទាំងអស់ ។ លោកក៏បានថ្លែងអំណរគុណ ចំពោះសមាជិកក្រុមប្រឹក្សាឃុំសង្កាត់ផងដែរ ។ ខប់សែលដំណាក់កាលទី២ នឹងពិភាក្សាលើបញ្ហាជាក់លាក់មួយចំនួន ដែលត្រូវផ្សព្វផ្សាយតាមបណ្តាញសារពត៌មានផងដែរ ហើយលោកបានអរគុណចំពោះទូរទស្សន៍ CTN ជាពិសេសកម្មវិធី "កម្ពុជាថ្ងៃនេះ" ដែលបានផ្តល់បទសំភាសន៍ដល់រូបលោក និងលោកនាយក CDRI កាលពីថ្ងៃទី៧ កក្កដា ២០០៥ ។ លោកសង្កត់ធ្ងន់ថា តាមរយៈការរួមចំណែកទាំងនេះ យើងនឹងខិតខំព្យាយាមធ្វើអោយខប់សែល ឈានបន្តិចម្តងៗពីយន្តការបង្ការទំនាស់ទៅជាយន្តការដោះស្រាយទំនាស់ ។

លោក **ឱក សេរី សោភក្តិ៍** បានបញ្ជាក់បន្ថែមថា ខប់សែលទី ១ ទទួលបានជោគជ័យក្នុងរយៈពេល ៥ឆ្នាំកន្លងមក គឺដោយសារមានឆន្ទៈនយោបាយដ៏មុតមាំពីភាគីពាក់ព័ន្ធ ជាពិសេសពីរាជរដ្ឋាភិបាលកម្ពុជា ។ លោកបានសំដែងការគោរពដឹងគុណជាពិសេសដល់សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** និងក្រសួងមហាផ្ទៃ ដែលបានផ្តល់ការគាំទ្រ និងសហការជាបន្តបន្ទាប់ ។ លោកជឿជាក់ថា ភាគីទាំងអស់ នឹងមានឆន្ទៈកាន់តែរឹងមាំថែមទៀត ដើម្បីជាប្រយោជន៍ដល់ការបោះឆ្នោតប្រកបដោយលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដែលជាមូលដ្ឋាននៃស្ថិរភាពនយោបាយ និងសង្គមទាំងមូល ។ លោកបានជំរាបជូនអង្គសន្និសីទថា ការបង្ការនិងដោះស្រាយទំនាស់ ទាមទារពេលវេលា និងការតាំងចិត្តពីគ្រប់ភាគីពាក់ព័ន្ធ ជាពិសេសក្នុងការចូលរួមពិភាក្សាគ្នា ហើយវប្បធម៌នៃការពិភាក្សាគ្នានេះ គឺជាផ្នែកចំបងមួយនៃវប្បធម៌សន្តិភាព ។ តាមរយៈខប់សែលនេះ វិទ្យាស្ថាន CDRI អាចផ្តល់នូវវេទិកាសេរី និងអព្យាក្រឹត្យ ដើម្បីអោយភាគីអាចជជែកពិភាក្សាគ្នាដោយចំហ និងដោយពុំមានការភ័យខ្លាច ។ នៅទីបញ្ចប់ លោកសង្ឃឹមថា យន្តការខប់សែលនេះនឹងក្លាយជាបទពិសោធន៍ដ៏មានប្រយោជន៍សំរាប់កម្ពុជា ដែលនឹងមិនត្រឹមតែមានសារៈសំខាន់សំរាប់ការបោះឆ្នោតប៉ុណ្ណោះទេ តែក៏អាចយកទៅអនុវត្តនៅក្នុងវិស័យផ្សេងៗទៀតដែរ ហើយសង្ឃឹមថា បណ្តាប្រទេសផ្សេងទៀតដែលមានស្ថានភាពស្រដៀងគ្នានឹងកម្ពុជា អាចរៀនសូត្រពីបទពិសោធន៍នេះផងដែរ ។ លោកបានថ្លែងអំណរគុណផងដែរដល់ព្រឹទ្ធសភា និងរដ្ឋសភាជាតិ ជាពិសេសសម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ដែលបានបន្តគាំទ្រដល់ដំណើការខប់សែល និងដល់សម្តេច **នរោត្តម សេរីវុឌ្ឍ** ដែលព្រះអង្គតែងខ្នះខ្នែងឆ្លើយតបយ៉ាងរួសរាន់ទៅនឹងសំណើរបស់ ខប់សែល ។ លោក **ឱក សេរី សោភក្តិ៍** ក៏បានថ្លែងអំណរគុណ និងការគោរពផងដែរ ដល់គណបក្សសមរង្ស៊ី និងសូមផ្តាំផ្ញើពាក្យសំដីនេះទៅឯកឧត្តម សម រង្ស៊ី តាមរយៈតំណាងដែលចូលរួមក្នុងសន្និសីទ ចំពោះការបន្តចូលរួម និងគាំទ្រដល់ខប់សែល ។

## សុន្ទរកថាស្វាគមន៍របស់លោក Larry Strange នាយកប្រតិបត្តិរបស់ CDRI:

ក្នុងនាមវិទ្យាស្ថាន CDRI លោក Larry Strange បានសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅដល់គណៈអធិបតី និងភ្ញៀវកិត្តិយស់ទាំងអស់ដែលបានចូលរួមក្នុងអង្គសន្និសីទ ។ នៅក្នុងសុន្ទរកថា លោកនាយកវិទ្យាស្ថាន បានជំរាបជូនអង្គសន្និសីទថា ហេតុអ្វីបានជាខប់សែលមានសារៈសំខាន់ ។ លោកបានបញ្ជាក់ថា ហេតុផលទីមួយគឺថា ខប់សែល ធ្លាប់សំរេចបាននូវលទ្ធផលយ៉ាងល្អប្រសើរ ហើយយន្តការនេះត្រូវបានដឹងថាផ្តួចផ្តើម និងគ្រប់គ្រងដោយកម្ពុជា ហើយជាកម្មសិទ្ធិរបស់កម្ពុជា ។ ខប់សែលមិនមែនជាការកែសំរួលចេញពីយន្តការ ឬវិធីសាស្ត្រ

ផ្សេងណាដើម្បីតំរូវតាមស្ថានភាពរបស់កម្ពុជានោះទេ ហើយក៏មិនរងឥទ្ធិពលពីមនោគមន៍វិជ្ជាខាងក្រៅ ដែលចង់អោយកម្ពុជាធ្វើយ៉ាងនេះ ឬយ៉ាងនោះ ឬឆ្ពោះទៅទិសដៅណាមួយ និងតាមរបៀបណានោះដែរ ។ ខប់សែលជាស្នាដៃរបស់កម្ពុជាសុទ្ធសាធ ។

ហេតុផលទី ២ គឺថាខប់សែលមានលក្ខណៈឆ្លើយតបទៅនឹងស្ថានភាពរបស់កម្ពុជា ។ គោលដៅចំបងរបស់ខប់សែល គឺបង្ការទំនាស់ អំពើហិង្សា និងការយល់ច្រឡំពីគ្នា នៅក្នុងដំណើរការបោះឆ្នោត តាមរយៈការកសាងទំនុកចិត្ត និងការបង្កើត ឡើងនូវវប្បធម៌ពិភាក្សាគ្នា ។ ទាំងនេះជាធាតុផ្សំដ៏ពិសេសរបស់ ខប់សែល ។ ចំណុចខ្លាំងមួយរបស់ ខប់សែល គឺភាពជាក់លាក់អំពីសមត្ថភាពរបស់ខ្លួន ព្រោះខប់សែល មិនអះអាងថា អាចដោះស្រាយបញ្ហាបានគ្រប់យ៉ាងនៃការបោះឆ្នោតនោះទេ តែគ្រាន់តែជួយបង្ការទំនាស់ និងរួមចំណែកអោយការបោះឆ្នោតមានលក្ខណៈសេរី និងយុត្តិធម៌ ។

ហេតុផលមួយទៀត គឺថាខប់សែលត្រូវបានគាំទ្រដោយការសិក្សាស្រាវជ្រាវប្រកបដោយគុណភាព និងអព្យាក្រឹត្យរបស់វិទ្យាស្ថាន CDRI ផ្ទាល់ ។ កាលពីដំបូងខប់សែលនេះកើតឡើងពីការសិក្សាស្តីពី *ចរិត និងមូលហេតុនៃការរីករាលដាលទំនាស់នៅក្នុងការបោះឆ្នោតជាតិឆ្នាំ១៩៩៨* និង *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រងទំនាស់នៅកម្ពុជា: ការសិក្សាប្រៀបធៀបការបោះឆ្នោតបីរបស់កម្ពុជា* ។ ការសិក្សាទាំងនេះ ជាធនធានដ៏សំខាន់សំរាប់អ្នករៀបចំគោលនយោបាយ គណបក្សនយោបាយ និងអង្គការតស៊ូមតិផ្សេងៗទៀត ។

បន្ទាប់ពីបកស្រាយជូនពីសារៈសំខាន់នៃយន្តការខប់សែល លោកនាយកវិទ្យាស្ថានបានសំដែងអំណរគុណ និងការកោតសរសើរដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ដែលបានធ្វើអោយខប់សែលដំណាក់កាលទី ២ នេះដំណើរការទៅបានតាំងពីពេលពិគ្រោះយោបល់ រហូតបានចេញជារូបរាង ក្នុងនោះរួមមាន គ.ជ.ប មន្ទីរនិងស្ថាប័នរបស់រដ្ឋាភិបាល គណបក្សនយោបាយធំៗ អភិបាលនិងអភិបាលរងខេត្ត-ក្រុង សមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ និងថ្នាក់ដឹកនាំអង្គការសង្គមស៊ីវិលដែលពាក់ព័ន្ធក្នុងការឃ្លាំមើលការបោះឆ្នោត ។ លោក Larry Strange ក៏បានថ្លែងអំណរគុណជាពិសេសដល់ ្ណឧភ ដែលបានផ្តល់ថវិកា សំរាប់ដំណើរការខប់សែលដំណាក់កាលទី ២ នេះ ជាពិសេសចំពោះលោក ឡុងលាស អារដនរេ តំណាងប្រចាំប្រទេសកម្ពុជា និងលោកស្រី ប៉ុក បញ្ញាវិចិត្រ ។ នៅទីបញ្ចប់ លោកបានថ្លែងអំណរគុណដល់ លោក **ឱក សេរី សោភ័ក្តិ** ដែលបច្ចុប្បន្នជាទីប្រឹក្សារបស់វិទ្យាស្ថាន CDRI ក្នុងគំរោងនេះ ដែលបន្តឆន្ទៈយ៉ាងមោះមុតចំពោះយន្តការខប់សែល ។

## បទអន្តរាគមន៍របស់លោកស្រី Anne-Isabelle Degryse-Blateau ប្រធានកម្មវិធីនិងតំណាង UNDP

ជំនួសមុខអោយអង្គការ UNDP លោកស្រី **Anne-Isabelle Degryse-Blateau** បានមានប្រសាសន៍ថា ដោយសារបានចូលរួមយ៉ាងសកម្ម នៅក្នុងខប់សែលដំណាក់កាលទី១ អង្គការ UNDP មានសេចក្តីរីករាយដែលបានឃើញការដំណើរការឡើងវិញនូវយន្តការខប់សែលក្នុងរូបភាពថ្មី និងមានលក្ខណៈទូលំទូលាយជាងមុន ។ ទំរង់ថ្មីនៃខប់សែល ដែលនឹងត្រូវអនុវត្តដោយ CDRI នេះ គឺស្ថិតក្នុងក្របខ័ណ្ឌគំរោង Insights for Action របស់ UNDP ហើយនេះជាការឆ្លុះបញ្ចាំងអោយឃើញយ៉ាងច្បាស់នូវការបន្តការតាំងចិត្តរបស់ UNDP ក្នុងការជ្រោមជ្រែង និងផ្តល់ជំនួយបច្ចេកទេស ដើម្បីកែលំអដំណើរការបោះឆ្នោត និងលើកកំពស់លទ្ធិប្រជាធិបតេយ្យនៅក្នុងប្រទេសកម្ពុជា និងដោយប្រជាជនកម្ពុជា ។

ផ្អែកតាមបទពិសោធន៍ពីការផ្តល់ជំនួយបច្ចេកទេសសំរាប់ការបោះឆ្នោតកន្លងមក យើងជឿជាក់ថា មានតំរូវការចាំបាច់ណាស់ក្នុងការបង្កើតឡើងនូវបរិយាកាសអព្យាក្រឹត្យមួយ សំរាប់ពិភាក្សានូវរាល់ចំណោទបញ្ហាទាំងអស់ដែលទាក់ទងនឹងការបោះឆ្នោត ។ ក្នុងន័យនេះ ដំណើរការខប់សែលដែលត្រូវបានអនុវត្តមុនឆ្នាំ២០០៣ គឺជាគំរូមួយដ៏ល្អនៃការកសាងបរិយាកាសប្រជាធិបតេយ្យ ។ យន្តការនេះបានផ្តល់ជូន គ.ជ.ប ជាលើកដំបូងនូវឧបករណ៍មួយសំរាប់ធ្វើការពិគ្រោះយោបល់យ៉ាងទូលំទូលាយនូវក្របខ័ណ្ឌច្បាប់នៃការបោះឆ្នោត ហើយដំណើរការនោះត្រូវបានវាយតំលៃខ្ពស់ពីសំណាក់ប្រជាជនកម្ពុជា និងសហគមន៍អន្តរជាតិ ។ លោកស្រីបន្ថែមថា នេះជាពេលវេលាសមស្រប សំរាប់ចាប់ផ្តើមខប់សែលដំណាក់កាលទី២ ដើម្បីអោយភាគីពាក់ព័ន្ធទាំងអស់មានឱកាសពិភាក្សាគ្នា ដើម្បីធ្វើអោយប្រសើរដល់ការបោះ

ឆ្នោតទាំងបីខាងមុខ ។ យន្តការនេះទៀតសោត ក៏ស្របនឹងយុទ្ធសាស្ត្ររបស់ UNDP ដែលនឹងត្រូវប្តូរពីការផ្តោតលើព្រឹត្តិការជាក់លាក់ក្នុងរយៈពេលខ្លី ទៅជាសកម្មភាពទូលំទូលាយសំរាប់រយៈពេលវែង ។

បញ្ហាមួយក្នុងចំណោមបញ្ហាដទៃទៀតដែលកម្ពុជាកំពុងប្រឈមមុខ គឺកម្ពុជានៅមានវប្បធម៌ប្រជាធិបតេយ្យកំរិតទាបនៅឡើយ ដែលនេះជាកត្តាដ៏សំខាន់សំរាប់សំរេចអោយបាននូវលទ្ធិប្រជាធិបតេយ្យពេញលេញ ។ ជំហានមួយឆ្ពោះទៅដោះស្រាយបញ្ហានេះគឺ UNDP ត្រូវរៀបចំអនុវត្តកម្មវិធីមួយដែលមានលក្ខណៈទូលំទូលាយឈ្មោះថា Between the Ballot Boxes ដើម្បីកែលំអលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។ កម្មវិធីនេះមានបំណងពង្រឹងសមត្ថភាពថ្នាក់ដឹកនាំរបស់ គជប ពង្រឹងក្របខ័ណ្ឌច្បាប់ និងដំណើរការបោះឆ្នោត និងលើកកំពស់ការចូលរួមរបស់មហាជន ។

លោកស្រី **Anne-Isabelle Degryse-Blateau** បានបញ្ជាក់ទៀតថា លទ្ធិប្រជាធិបតេយ្យមិនអាចកើតមានក្នុង រយៈពេលដ៏ខ្លីបានទេ ហើយការមានការបោះឆ្នោតដែលត្រឹមត្រូវ និងយុត្តិធម៌បំផុត ក៏នឹងមិនធានាថា លទ្ធិប្រជាធិបតេយ្យកើតមានជាស្វ័យប្រវត្តិដែរ ។ ការបោះឆ្នោតគ្រាន់តែជាជំហានមួយឆ្ពោះទៅលទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះ ។ ដូច្នេះអ្វីដែលត្រូវការបំផុត គឺការផ្លាស់ប្តូរផ្នត់គំនិតឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យពេញលេញ ។ ឯការបណ្តុះផ្នត់គំនិតនេះ ត្រូវធ្វើឡើងចាប់តាំងពីដំណាក់កាលដំបូងនៃជីវិតរបស់មនុស្ស ពោលគឺនៅតាមសាលារៀន ។ លោកស្រីកត់សំគាល់ថា ការផ្តល់ជំនួយដល់ការបោះឆ្នោតនៅតែជាចំណុចរសើបនៅគ្រប់ប្រទេស ដែលហេតុនេះហើយវិភាគទានរបស់ UNDP ដល់ការកសាងលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ត្រូវតែមានតម្លាភាព និងយល់អោយបានច្បាស់ពីភាគីទាំងអស់ ។ ដោយមើលឃើញពីការចូលរួមយ៉ាងទូលំទូលាយនៅក្នុងអង្គសន្និសីទ លោកស្រីមានប្រសាសន៍ថា ខប់សែលកំពុងមានការចាប់ផ្តើមយ៉ាងល្អ ហើយសង្ឃឹមថា កិច្ចប្រជុំខប់សែល នឹងទទួលបានផ្លែផ្កាជាដុំកំភួន ។

## សុន្ទរកថាបើកអង្គសន្និសីទរបស់ឯកឧត្តម អ៊ឹម សួស្តី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ក្នុងនាម គ.ជ.ប ឯកឧត្តម **អ៊ឹម សួស្តី** បានសំដែងនូវការកោតសរសើរដល់យន្តការខប់សែល ដែលបានខិតខំស្វែងរកការគាំទ្រសំរាប់ដំណើរការដំណាក់កាលទី ២ របស់ខ្លួន ។ ឯកឧត្តមមានប្រសាសន៍ថា នៅដំណាក់កាលទី ១ ខប់សែលបានបំពេញតួនាទីដ៏ឧត្តុង្គឧត្តមក្នុងការស្វែងរកគ្រប់មធ្យោបាយក្នុងការបង្ការទំនាស់ក្នុងពេលបោះឆ្នោត និងជួយសំរួលដល់ការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០២ និងការបោះឆ្នោតជាតិឆ្នាំ២០០៣ ។

ឯកឧត្តមទទួលស្គាល់ថា គ្រប់ការរៀបចំការបោះឆ្នោតតែងតែកើតមានទំនាស់ ពោលគឺចាប់ពីដំណាក់កាលដំបូង រហូតដល់ពេលប្រកាសលទ្ធផល ប៉ុន្តែ ខប់សែលបានលើកយកពីប្រភពទំនាស់ និងរៀបចំអោយមានការពិភាក្សាគ្នាដើម្បីរកវិធីដោះស្រាយ ។ ក្នុងនាម គ.ជ.ប ឯកឧត្តម បានសំដែងការគាំទ្រដល់វត្តមានជាថ្មីរបស់ ខប់សែល ហើយសង្ឃឹមថាយន្តការនេះ នឹងបំពេញតួនាទីដ៏សំខាន់របស់ខ្លួនក្នុងការបង្ការ និងរកដំណោះស្រាយទំនាស់ ព្រមទាំងបង្កើនជំនឿទុកចិត្តពីគ្រប់ភាគីទាំងអស់ ។ ឯកឧត្តមសង្ឃឹមថា បទពិសោធន៍ទាំងនេះនឹងត្រូវចែករំលែកជាមួយ គ.ជ.ប ព្រោះថាក្រៅពីការខិតខំពង្រឹងសមត្ថភាពលើគ្រប់ផ្នែកនៃការបោះឆ្នោត, មន្ត្រី គ.ជ.ប គ្រប់លំដាប់ថ្នាក់បានបន្តពង្រឹងកិច្ចសហការជាមួយគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ។

ឯកឧត្តមសង្ឃឹមថា វាគ្មិនក្នុងសន្និសីទ នឹងលើកយកមកពិភាក្សានូវបញ្ហានានាដែលនឹងអាចកើតមានឡើងក្នុងពេល បោះឆ្នោតទាំងបីខាងមុខ ។ ការបង្ការ និងដោះស្រាយទំនាស់នេះ គឺជាចំណុចអាទិភាពរបស់ គ.ជ.ប, ហើយ គ.ជ.ប នឹងដាក់ចេញនូវវិធានការណ៍ថ្មីៗ ដើម្បីអោយការបោះឆ្នោតទាំងនេះកាន់តែមានលក្ខណៈល្អប្រសើរ ។ ទន្ទឹមនឹងនេះឯកឧត្តមសង្ឃឹមថា ខប់សែល នឹងបំផុសគំនិត និងមានអនុសាសន៍ថ្មីៗ ដើម្បីបំពេញបន្ថែមចំណុចខ្វះខាតកន្លងមក និងធ្វើអោយប្រសើរដល់ការបោះឆ្នោតខាងមុខ ។ នៅទីបញ្ចប់ ឯកឧត្តមបានសំដែងនូវអំណរគុណជាថ្មីដល់យន្តការខប់សែល និងបានប្រកាសបើកអង្គសន្និសីទ ។

*មតិរបស់លោក ឱក សេរី សោភក្តិ*

នៅចុងបញ្ចប់នៃកម្មវិធីបើកអង្គសន្និសីទ លោក **ឱក សេរី សោភក្តិ** បានថ្លែងអំណរគុណដល់គណៈអធិបតី ពិសេសឯកឧត្តម **អ៊ឹម សួស្តី** ដែលបានប្រកាសបើកអង្គសន្និសីទ និងដំណើរការយន្តការខប់សែលក្នុងរយៈពេលបីឆ្នាំខាងមុខ ។ លោកសូមអោយអង្គសន្និសីទរក្សាទុកនូវពាក្យពេចន៍ទាំងនេះ ។ លោកក៏កត់សំគាល់ឃើញផងដែរថា គណបក្សធំៗទាំងបីកន្លងមកមានទំនាក់ទំនងល្អជាមួយគណបក្សប្រជាធិបតេយ្យខ្មែរ ហើយ CDRI មានក្តីរំភើប និងចង់ឃើញកិច្ចសហប្រតិបត្តិការនេះមានតទៅទៀតក្នុងយន្តការខប់សែលដំណាក់ទី ២ ។

## ការពិភាក្សាអំពី "ទំនាស់ដែលអាចកើតមានក្នុងដំណើរការបោះឆ្នោតទាំងបីខាងមុខនៅកម្ពុជា និងនីតិវិធីជាយុទ្ធសាស្ត្រដើម្បីដោះស្រាយ"

***ក្រុមឱ្យទ្ទេសនាមទី ១:***

១. **ឯកឧត្តម ប៉ែន បញ្ញា**

**សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មការកណ្តាលនៃគណបក្ស ប្រជាជនកម្ពុជា**

**និងប្រធានគណៈកម្មការការពារសិទ្ធិមនុស្ស និងទទួលពាក្យបណ្តឹងនៃរដ្ឋសភា**

ក្នុងនាមគណបក្សប្រជាជនកម្ពុជា ឯកឧត្តមមានកិត្តិយស និងសេចក្តីរីករាយក្នុងការចូលរួមឧទ្ទេសនាមអំពីប្រធានបទខាងលើនេះ ។ ឯកឧត្តមចាប់ផ្តើមដោយការរំលឹកដល់ព្រឹត្តិការណ៍នយោបាយក្នុងមួយទសវត្សរ៍កន្លងមក ពោលគឺការបោះឆ្នោតតាមបែបសេរី និងប្រជាធិបតេយ្យទាំង ៤លើកកន្លងមក ដែលនោះឆ្លុះបញ្ចាំងពីការជឿជាក់ដ៏មុតមាំរបស់ប្រជាជន និងរាជរដ្ឋាភិបាលក្នុងការឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ ។ បីឆ្នាំខាងមុខនេះ កម្ពុជាត្រូវរៀបចំការបោះឆ្នោតបីបន្ថែមទៀត ដែលនេះជាសក្ខីកម្មនៃការចាក់ឫសកាន់តែជ្រៅថែមទៀតនៃលទ្ធិប្រជាធិបតេយ្យនៅកម្ពុជា ។

ក្នុងគ្រប់ដំណើរការនៃការបោះឆ្នោតនៅប្រទេសប្រជាធិបតេយ្យ តែងតែមានសំណូមពរអំពីការបង្ការទំនាស់ និងប្រសិទ្ធិភាពដោះស្រាយទំនាស់ និងការជៀសវាងភាពមិនប្រក្រតីនានា ។ ដូច្នេះក្នុងគ្រប់ការបោះឆ្នោត តួអង្គទាំងអស់ត្រូវ:

- គោរពអោយបានត្រឹមត្រូវនូវច្បាប់ គោលការណ៍ បទបញ្ជា ក្រមសីលធម៌ និងសេចក្តីណែនាំដែលពាក់ព័ន្ធ ។
- មានការយល់ដឹងច្បាស់ និងទាន់ពេលនូវគោលការណ៍ និងពត៌មាន ដែលនេះមានសារៈសំខាន់ណាស់ សំរាប់អ្នកបោះឆ្នោត និងអង្គបោះឆ្នោត ។
- ពង្រឹងសមត្ថភាព និងប្រសិទ្ធិភាពការងាររបស់ គ.ជ.ប ស្របតាមមាត្រា ១១ នៃច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ឯការបោះឆ្នោតក្រុមប្រឹក្សាឃុំសង្កាត់ ក៏មានការចែងច្បាស់ពីតួនាទី និងសមត្ថកិច្ចរបស់ គ.ជ.ប ដែរ គឺ នៅមាត្រា ៧ ។
- បង្កើតការអប់រំ និងការយល់ដឹងជាសាធារណៈ អំពីយន្តការ នីតិវិធី ផែនការ និងរបៀបវារៈដែលដាក់ ចុះដោយ គ.ជ.ប ពិសេសចំពោះអាជ្ញាធរមូលដ្ឋាន និងប្រធានភូមិ ។
- គោរពអោយបានហ្មត់ចត់នូវបណ្តាច្បាប់ បទបញ្ជា និងក្រមសីលធម៌ដែលបានកំណត់ និងប្រកាន់ឥរិយាបថដែលមិននាំអោយមានអំពើហិង្សា និងប៉ះពាល់អ្នកដទៃ ។
- ខិតខំដោះស្រាយវិវាទអោយបានដាច់ស្រេចតាមករណីនីមួយៗ និងតាមកំរិតផ្សេងៗស្របតាមនីតិវិធី និងបញ្ញត្តិជាធរមាន ។
- គោរព និងមានសេចក្តីក្លាហានទទួលស្គាល់ និងទទួលយកលទ្ធផលនៃការបោះឆ្នោត ។

- ការបង្ការទំនាស់ និងដោះស្រាយទំនាស់បានត្រឹមត្រូវនឹងជួយរួមចំណែកកាត់បន្ថយភាពមិនប្រក្រតី និងលើកកំពស់គណនេយ្យភាព និងតំលៃនៃជោគជ័យក្នុងការបោះឆ្នោត ។ ជាទីបញ្ចប់ ឯកឧត្តមថ្លែងអំណរគុណដល់ភាគីពាក់ព័ន្ធទាំងអស់ដែលបានរួមចំណែកធ្វើអោយការបោះឆ្នោតទាំងបួនលើកទទួលបានជោគជ័យ និងសូមតំកល់ការជឿជាក់លើការខិតខំរួមនេះទៅអនាគត ដើម្បីលើកស្ទួយវប្បធម៌ប្រជាធិបតេយ្យតាមរយៈសំលេងឆ្នោតនៅកម្ពុជា ។

## ២. ឯកឧត្តម **ឆា ចំរ៉ាត់**

### អគ្គលេខាធិការរងនៃគណបក្សហ្វ៊ុនស៊ិនប៉ិច

### និងអនុប្រធាន គណៈកម្មការមហាផ្ទៃ ការពារជាតិ អង្កេត និងបោសសំអាតនៃព្រឹទ្ធសភា

ឯកឧត្តម **ទា ចំរ៉ាត់** បានធ្វើការកត់សំគាល់ថា កម្ពុជាបានរៀបចំការបោះឆ្នោត ៤ដងមកហើយ តែបញ្ហាដែលជួបប្រទះ គឺនៅមានកើតឡើងដដែល១ ។ ឯកឧត្តមបានផ្តោតទៅលើមូលដ្ឋានពីរៈ មូលដ្ឋានបញ្ហា និងដំណោះស្រាយ ។

ចំពោះមូលដ្ឋានបញ្ហា ឯកឧត្តមកត់សំគាល់ឃើញមានបញ្ហាតាំងពីពេលចុះបញ្ជីឈ្មោះអ្នកបោះឆ្នោតរហូតដល់ពេលរាប់សន្លឹកឆ្នោត ។ ក្នុងពេលចុះឈ្មោះមានបញ្ហាដូចជា ស្មៀនឃុំ-សង្កាត់មានការធុញថប់ក្នុងការងារនេះ ការបាត់ឈ្មោះក្នុងបញ្ជី និងការតវ៉ាពុំបានសំរេច ការសរសេរឈ្មោះច្រឡំ និងការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតលើកដំបូង ។ បញ្ហាមួយទៀត គឺទាក់ទិននឹងយន្តការឃោសនាបោះឆ្នោត និងការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោតមុនថ្ងៃបោះឆ្នោត ។ ចំណុចនេះរួមមាន ការភ័យខ្លាច ការប្រាសចាកក្រមសីលធម៌ ការមិនគោរពបែបបទ និងនីតិវិធីដែលកំណត់ដោយ គ.ជ.ប ។ ឯបញ្ហាកើតនៅថ្ងៃបោះឆ្នោត រួមមាន ការរកឈ្មោះមិនឃើញដោយការប្តូរការិយាល័យបោះឆ្នោត ការបាត់ឈ្មោះពីបញ្ជីតាមការិយាល័យបោះឆ្នោត ការមិនអាចបោះឆ្នោតដោយស្មៀនឃុំ-សង្កាត់សរសេរឈ្មោះខុស ។ ក្រៅពីនេះក៏មានបញ្ហានៅពេលរាប់សន្លឹកឆ្នោតដែរ ដោយការរាប់ច្រឡំ ឬមានបំណងធ្វើអោយច្រឡំ, ការចោទប្រកាន់ថាលួចបន្លំសន្លឹកឆ្នោត ឬដូរហិបឆ្នោត និងការមានមតិដោយគ្មានមូលដ្ឋាន និងភស្តុតាង ។

រីឯមូលដ្ឋានដំណោះស្រាយវិញ រួមមានៈ (១) គ.ជ.ប គប្បីណែនាំស្មៀនឃុំ-សង្កាត់អោយចុះឈ្មោះអោយបានច្បាស់លាស់ មានយុត្តិធម៌ តម្លាភាព ហើយសរសេរឈ្មោះ លេខរៀង អាយុ ភេទ និងទំលំនៅ អោយបានត្រឹមត្រូវ ។ ក្រុមប្រឹក្សាឃុំសង្កាត់ដែលដោះស្រាយពាក្យបណ្តឹងនៃការចុះឈ្មោះ លុបឈ្មោះ ប្តូរទីតាំង គួរដោះស្រាយអោយដើមចោទ យល់ច្បាស់ ហើយគួរបន្ថែមចំនួនថ្ងៃអោយលើសពីមុន ។ ឯការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោត ត្រូវធ្វើអោយបានទូលំទូលាយ រួមទាំងការផ្សព្វផ្សាយចល័តផង ហើយត្រូវបន្ថែមថេរវេលាសំរាប់កិច្ចការនេះ ។ (២) ជៀសវាងកុំអោយមានការបំភិតបំភ័យពេលឃោសនាបោះឆ្នោត, ការផ្សព្វផ្សាយបែបបទ និងនីតិវិធីរបស់ គ.ជ.ប ត្រូវធ្វើអោយបានញឹកញាប់ទាំង សំណេរ និងសំលេង ហើយគួរបន្ថែមថេរវេលានៃការបិទផ្សាយបញ្ជីឈ្មោះអ្នកបោះឆ្នោត ។ (៣) គ.ជ.ប គួរចាត់ចែងអោយមានមធ្យោបាយនៅថ្ងៃបោះឆ្នោត សំរាប់អ្នកខ្វះមធ្យោបាយធ្វើដំណើរ និងអ្នកមិនចេះអក្សរ ដើម្បីបោះឆ្នោតទាន់ពេល ។ (៤) ការរាប់សន្លឹកត្រូវធ្វើអោយបានច្បាស់ អាចមើលឃើញគ្រប់គ្នា និងពុំត្រូវធ្វើដោយរួសរាន់ពេកទេ ។ (៥) អ្នកបញ្ចេញមតិដោយគ្មានមូលដ្ឋានច្បាស់លាស់ គួរប្រយ័ត្នដើម្បីកុំអោយមានការភ័ន្តច្រឡំក្នុងចំណោមមហាជន ។ (៦) សមាសភាព គ.ជ.ប គប្បីទទួលការតែងតាំងរយៈពេល ១០ខែមុន ដើម្បីអោយមានពេលគ្រប់គ្រាន់រៀបចំកិច្ចការបោះឆ្នោតបានត្រឹមត្រូវ ។

## ៣. ឯកឧត្តម **ទេព នីថា**

### អគ្គលេខាធិការ នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ឯកឧត្តម **ទេព នីថា** បានធ្វើការកត់សំគាល់ទៅលើបួនចំណុចសំខាន់១ ។ ចំណុចទី ១ ឯកឧត្តមពិនិត្យមើលទៅលើបរិយាកាសនៃការបោះឆ្នោត ដោយមានប្រសាសន៍ថា កម្ពុជាបានរៀបចំការបោះឆ្នោតដោយខ្លួនឯងចំនួន ៣ដងរួចមកហើយ ពីការបោះឆ្នោតមួយទៅមួយមាន

ការរីកចំរើនជាលំដាប់ទាំងផ្នែកគ្រប់គ្រងបច្ចេកទេស ការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយពីសំណាក់គណបក្ស ការអនុវត្តបានល្អតាមពេលវេលា និងមានការថយចុះនូវអំពើហិង្សាផងដែរ ។ តែទោះជាយ៉ាងណាក្តី យើងនៅតែមានការខ្វះខាតខ្លះដែលត្រូវកែលំអ ។ ថ្វីបើការបោះឆ្នោតព្រឹទ្ធសភា តាមបែបអសាកលនៅឆ្នាំក្រោយ មិនសូវជាមានបញ្ហាក្តី ក៏ការបោះឆ្នោតពីរទៀតតំរូវអោយមានការកែលំអខ្លះដែរ ជាពិសេសផ្នែកច្បាប់ ។ ឯកឧត្តមបញ្ជាក់ថា ច្បាប់បោះឆ្នោតតំណាងរាស្ត្រ ត្រូវបានធ្វើវិសោធនកម្មនៅឆ្នាំ២០០២ ដោយកែលំអរចនាសម្ព័ន្ធ គ.ជ.ប និងនីតិវិធីចុះឈ្មោះអ្នកបោះឆ្នោតដែលផ្តល់អំណាចអោយក្រុមប្រឹក្សាឃុំសង្កាត់អនុវត្តកិច្ចការនេះ តែច្បាប់បោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ពុំទាន់មានការធ្វើវិសោធនកម្មទេ ដែលនេះតំរូវអោយមានការពិនិត្យមើលឡើងវិញ ។ ឯកឧត្តមបានបញ្ជាក់ទៀតថា គ្មានការបោះឆ្នោតណាប្រព្រឹត្តិទៅដោយគ្មានទំនាស់ទេ ។ ដោយយល់ដូចនេះហើយ ទើប គ.ជ.ប បានយកចិត្តទុកដាក់ជានិច្ចកាលលើបញ្ហានេះ ដោយដាក់ចេញជាវិធានការណ៍ថ្មីៗសំរាប់បញ្ហានេះ ។

ចំណុចទីពីរ ឯកឧត្តម បានផ្តោតទៅលើទំនាស់ដែលអាចកើតមាននៅពេលបោះឆ្នោត ។ តាមបទពិសោធន៍នៃការខ្វះខាតកន្លងមក យើងគិតថា ទំនាស់ចាស់នឹងនៅតែកើតមានជាថ្មី គ្រាន់តែមានកំរិតផ្សេងគ្នា ហើយទំនាស់ថ្មីៗទៀត ក៏នឹងកើតមានដែរ ។ ដោយមិនបាច់លើកឡើងជាថ្មីនូវអ្វីដែលឯកឧត្តម **ទា ចំរ៉ាត់** ទើបតែមានប្រសាសន៍ ឯកឧត្តម **ទេព នីថា** លើកឡើងពីទំនាស់ដែលទាក់ទងនឹងការចុះឈ្មោះអ្នកបោះឆ្នោត ការខ្វះឯកសារបោះឆ្នោត ភាពយឺតយ៉ាវ ការដែលស្មៀនឃុំ-សង្កាត់ មិនសូវយកចិត្តទុកដាក់ និងបញ្ហានៃបញ្ជីបោះឆ្នោត ។ កន្លងមក គ.ជ.ប បានធ្វើការយ៉ាងជិតស្និទ្ធជាមួយភាគីពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាទាំងនេះ ដោយគិតទាំងបញ្ហានៃការប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយ និងការចោទប្រកាន់ពីការទិញសន្លឹកឆ្នោតផង ។ ឯបញ្ហាដែលទាក់ទងនឹងការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផល រួមមាន ការរកឈ្មោះក្នុងបញ្ជីមិនឃើញ ការខ្វះឯកសារបោះឆ្នោត ការអប់រំប្រជាជនមិនគ្រប់គ្រាន់ និងមិនទាន់ពេល ការគំរាមកំហែង និងការរើសអើង អំពើហិង្សា និងអសន្តិសុខ ចាប់ពីមុន រហូតដល់ក្រោយពេលបោះឆ្នោត ។

ចំណុចទី ៣ គឺជាយុទ្ធវិធីដោះស្រាយទំនាស់ ។ ក្នុងចំណុចនេះឯកឧត្តមមានប្រសាសន៍ថា ការប្រមើលមើលពីលទ្ធភាពនៃការកើតមានទំនាស់ ពាក្យបណ្តឹង មូលហេតុទំនាស់ ផលប៉ះពាល់នៃទំនាស់ និងទំនាក់ទំនងផ្សេងៗទៀត គឺជាកត្តាសំខាន់ណាស់ក្នុងការគ្រប់គ្រងការបោះឆ្នោត ។ ក្នុងការបង្ការទំនាស់ យើងត្រូវបង់នូវតំលៃមុន ទាំងធនធានមនុស្ស ថវិកា និងពេលវេលា ហើយដឹងថាទទួលលទ្ធផលល្អនៅពេលដែលបណ្តឹង និងទំនាស់ថយចុះ ។ ចំណែកឯការដោះស្រាយទំនាស់ ត្រូវធ្វើអោយទាន់ពេលវេលា ព្រោះថា ក្នុងការបោះឆ្នោតបើយើងមិនអាចបញ្ចប់ដំណាក់កាលមួយណាទេ យើងពិបាកនឹងឈានទៅដំណាក់កាលមួយទៀតណាស់ ។ ការដោះស្រាយទំនាស់ជាផ្នែកមួយនៃអភិបាលកិច្ចល្អ, បើមានអភិបាលកិច្ចល្អ ការដោះស្រាយ ក៏នឹងល្អដែរ ។ ផ្នែកសំខាន់ៗមួយចំនួនទាក់ទងនឹងការដោះស្រាយទំនាស់ រួមមាន ការកសាងសមត្ថភាពស្ថាប័នបោះឆ្នោត និងស្ថាប័នពាក់ព័ន្ធ ទាំងផ្នែករចនាសម្ព័ន្ធ ជំនាញ ជំហរអព្យាក្រឹត្យ និងតម្លាភាព ដល់ទាំង គ.ជ.ប ស្ថាប័នរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល គណបក្សនយោបាយ កងកំលាំងប្រដាប់អាវុធ ។ ចំណុចមួយទៀត គឺការកែលំអច្បាប់ និងនីតិវិធី ដែល គ.ជ.ប តែងធ្វើការសិក្សាពីការបោះឆ្នោតមួយទៅការបោះឆ្នោតមួយ ដែលទាំងនេះសំខាន់ណាស់សំរាប់ការវិវត្តន៍នៃសភាពការណ៍ ។ ការបំពាក់សំភារៈបច្ចេកទេស ក៏មានសារៈសំខាន់ដែរ រួមទាំងការរៀបចំប្រព័ន្ធកុំព្យូទ័រ និងការរៀបចំឈ្មោះតាមអក្ខរក្រមខ្មែរផង ។ ចំណុចសំខាន់មួយទៀត គឺការពង្រឹងកិច្ចសហការជាមួយ និងក្នុងចំណោមស្ថាប័នដែលពាក់ព័ន្ធ ។ នេះមានលក្ខណៈស្រដៀងគ្នានឹងអ្វីដែលយើងធ្វើក្នុងយន្តការខប់សែលដែរ ពោលគឺយើងស្វែងរកបញ្ហា និងដំណោះស្រាយរួមគ្នា ។ ថ្វីបើយើងមានសមត្ថកិច្ចដោះស្រាយផ្សេងពីគ្នាមែន តែយើងក៏បានដឹង និងយល់ពីដំណើរការនេះដែរ ។ ចំណុចចុងក្រោយគឺ ការអប់រំអំពីការបោះឆ្នោតជាដំណើរការប្រជាធិបតេយ្យ ដូច្នេះប្រជាពលរដ្ឋក៏ត្រូវតែទទួលបាននូវការអប់រំដែរ ដើម្បី អោយមានលក្ខណៈប្រជាធិបតេយ្យ ។

## ៤. លោក **គល់ បញ្ញា**

### នាយកប្រតិបត្តិគណៈកម្មាធិការខុមហ្វ្រែល

លោក **គល់ បញ្ញា** មានប្រសាសន៍ដោយផ្ដោតទៅលើទិដ្ឋភាពពីរ គឺទិដ្ឋភាពនៃទំនាស់ និងអនុសាសន៍សំរាប់កែលំអ ពិសេសទាក់ទងនឹងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០៧ និងបោះឆ្នោតជាតិឆ្នាំ២០០៨ ។ លោកប្រមើលឃើញថា ស្ថានភាពនាពេលខាងមុខមិនសូវជាល្អណាស់ណាទេ ទាំងផ្នែកស្ថានភាពគោលជំហរ និងឥរិយាបថ ។ ការភ័យខ្លាច និងកង្វះអព្យាក្រឹតភាព នៅតែមានទាំងក្នុងដំណើរការ និងស្ថាប័ន ។ លោកសំគាល់ឃើញមានចរន្តមួយ គឺចរន្តជ្រុលនិយមដែលប្រកាន់បក្សជ្រុលពេក ហើយក្នុងនោះអ្នកឈ្នះអាចធ្វើអ្វីៗបានទាំងអស់ ។ អាជ្ញាធរមូលដ្ឋាន ជាពិសេសមេភូមិដែលជាផ្នែកគន្លឹះនោះ នៅមិនទាន់មានជំហរអព្យាក្រឹត្យនៅឡើយ ។ ក្រៅពីនេះនៅមានចន្លោះប្រហោងផ្នែកច្បាប់ ដែលនាំអោយមានការបកស្រាយខុសគ្នា ក៏ជាប្រភពនៃទំនាស់ ឯវិសមភាពខាងយេនឌ័រក្នុងសង្គម និងក្នុងថ្នាក់ដឹកនាំ ក៏ជាកត្តាមួយដែរ ។ អង្គការមិនមែនរដ្ឋាភិបាល បានមើលឃើញនូវចំណុចទាំងនេះ ហើយបានបង្កើតជាក្រុមមួយ ដើម្បីចងក្រងជាអនុសាសន៍សុំអោយមានការកែលំអ ។

អនុសាសន៍ទី ១ គឺការកែទំរង់ គ.ជ.ប ដើម្បីអោយមានការជឿទុកចិត្តឡើងវិញ ។ គ.ជ.ប គួរត្រូវបានបញ្ចូលក្នុងច្បាប់រដ្ឋធម្មនុញ្ញ ដើម្បីមានកិត្យានុកូលភាពខ្ពស់ ក្នុងការបំពេញសមត្ថកិច្ចរបស់ខ្លួនមានប្រសិទ្ធិភាព ។ គួរមានការពិនិត្យមើលឡើងវិញលើសមាសភាពរបស់ គ.ជ.ប ធ្វើយ៉ាងណាអោយការជ្រើសរើសត្រូវតាមលក្ខណៈបច្ចេកទេស ។ សមាសភាព គ.ជ.ប មិនគប្បីស្ថិតក្នុងគណបក្សណាមួយ ហើយត្រូវស្ថិតឆ្ងាយពីនយោបាយក្នុងថេរវេលាកំណត់មួយដែរ ដូចជា ១ ឬ ២ឆ្នាំ ។ គប្បីមានគណៈកម្មាធិការដោយឡែកមួយ ដើម្បីជ្រើសរើសសមាសភាព គ.ជ.ប បើទោះបីសភាជាតិ នៅតែសំរេចជាចុងក្រោយក្ដី ។ អនុសាសន៍ទី ២ គឺអំពីបញ្ជីអ្នកចុះឈ្មោះបោះឆ្នោត ។ បញ្ជីនេះសំខាន់ណាស់ ដោយក្រសួងមហាផ្ទៃ ត្រូវធ្វើបញ្ជីនេះអោយបានឆាប់រហ័ស ហើយត្រូវមានគុណភាពខ្ពស់ ដោយមានការត្រួតពិនិត្យពីក្រុមឯករាជ្យផង ។ អនុសាសន៍ទី ៣ ស្ដីពីដំណើរការឃោសនាបោះឆ្នោត ។ យុទ្ធនាការនេះ ច្រើនតែនាំអោយមានទំនាស់ ដូច្នេះត្រូវតែមានការកំណត់ពីគោលការណ៍ និងក្រមសីលធមិច្បាស់លាស់ ដើម្បីជៀសវាងការទិតៀនគ្នាដោយមិនសមហេតុផល ហើយន័យនៃពាក្យថា ការទិញសន្លឹកឆ្នោត ក៏មិនទាន់មានកំណត់ច្បាស់ដែរ ។ ឯការចំណាយសំរាប់ការឃោសនា ក៏មិនទាន់មានការត្រួតពិនិត្យច្បាស់លាស់ដែរ បើទោះបីមានចែងក្នុងច្បាប់គណបក្សនយោបាយក្ដី ។ អនុសាសន៍ទី ៤ គឺសុំអោយលុបចោលនូវគណៈកម្មាធិការសំរបសំរួលការសង្កេតការណ៍បោះឆ្នោត ព្រោះវត្តមាននៃគណៈកម្មាធិការនេះ នាំអោយមានប៉ះពាល់ដល់អព្យាក្រឹត្យភាពរបស់អង្គការដែលសង្កេតការណ៍ ។ អនុសាសន៍ទី ៥ គឺលោកសុំអោយកំលាំងសន្តិសុខ ដែលទាក់ទិននឹងការបោះឆ្នោតស្ថិតក្រោមបញ្ជាការរបស់ គ.ជ.ប ដើម្បីអោយខ្លួនអាចអនុវត្តបានពេញលេញនូវតួនាទីនេះ ។ នៅក្នុងអនុសាសន៍ទី ៦ សុំអោយមានការពិនិត្យឡើងវិញលើប្រព័ន្ធផ្សព្វផ្សាយ ដោយលើកទឹកចិត្តអោយប្រព័ន្ធផ្សព្វផ្សាយជាតិ និងឯកជនបានផ្ដល់សេវាយ៉ាងទូលាយដល់គ្រប់ភាគីពាក់ព័ន្ធ ។ អនុសាសន៍ទី ៧ ទាក់ទងនឹងការដោះស្រាយវិវាទ ដែលលោកសុំអោយដកសិទ្ធិអំណាច គជប ចេញពីការដាក់ទោសពិន័យ ព្រោះថា គ.ជ.ប មិនអាចធ្វើទៅកើតទេ ហើយក៏គ្មានប្រសិទ្ធិភាពដែរ ព្រោះ គ.ជ.ប ខ្វះសមត្ថកិច្ចផ្លូវច្បាប់ ។ គួរផ្ដល់កិច្ចការនេះទៅអោយតុលាការដែលមានស្រាប់ តែក្នុងនោះគួរបង្កើតអង្គជំនុំជំរះ ពិសេសសំរាប់ការបោះឆ្នោត ។ តែទោះជាយ៉ាងណាក្ដី គ.ជ.ប នៅតែមានសិទ្ធិសំរេចលទ្ធផលបោះឆ្នោត ហើយ គ.ជ.ប គួរបង្កើតអោយមាននាយកដ្ឋានអង្កេត និងចោទប្រកាន់មួយ បើទោះបីគ្មានអំណាចកាត់ក្ដីនៃបទល្មើសក៏ដោយ ។ អនុសាសន៍ទី ៨ គឺអំពីប្រព័ន្ធបោះឆ្នោត ពិសេសការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ដែលគួរតែអោយបុគ្គលដែលមិនស្ថិតក្នុងគណបក្សអាចចូលរួមប្រកួតប្រជែង ព្រោះបើគិតតែគណបក្ស យើងទាត់ចោលប្រជាជនមួយចំនួនទៀតដែលគេចង់ចូលរួមក្នុងដំណើរការនេះដែរ ។ អនុសាសន៍ចុងក្រោយ គឺអំពីការចូលរួមរបស់ស្ត្រីក្នុងបេក្ខភាព ដែលក្នុងចំណុចនេះ លោកសុំអោយមានចែងក្នុងច្បាប់អំពីនៃបេក្ខជនជាស្ត្រីចំនួន ៣០% និងពីលក្ខណៈសម្បត្តិចាំបាច់ ហើយបើបញ្ជីបេក្ខជនរបស់គណបក្សពុំមានចំណុចទាំងនេះ គឺសុំកុំអោយទទួលយក ហើយលេខរៀងបញ្ជី ក៏ត្រូវដាក់ឆ្លាស់គ្នាផងដែរ រវាងបុរស និងស្ត្រី ។

**សំណួរ**

លោក **គិត ទូច** មន្ត្រីកម្មវិធី (CLEC) មានសំណួរពីរទាក់ទងនឹងក្របខ័ណ្ឌច្បាប់ និងការបោះឆ្នោតព្រឹទ្ធសភា:

១. សង្គមស៊ីវិលមួយចំនួនចង់ដកខ្លួនចេញពីការសង្កេតការបោះឆ្នោតព្រឹទ្ធសភា ។ សំណួរផ្តោតទៅឯកឧត្តម **ទេព នីថា** និងលោក **គល់ បញ្ញា** ថាតើនឹងមានផលវិបាកអ្វីខ្លះបើសង្គមស៊ីវិលធ្វើដូច្នេះ ហើយក្របខ័ណ្ឌច្បាប់នោះមានបញ្ហាអ្វីខ្លះ?

២. អំពីក្របខ័ណ្ឌច្បាប់ - លោកធ្លាប់ឮ ឯកឧត្តម **ម៉ោញ សាផាន** និយាយពីការទទួលស្គាល់ក្រមព្រហ្មទណ្ឌចាស់ ។ ច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ មិនបានចែងច្បាស់ពីសមត្ថកិច្ចដោះស្រាយជំលោះព្រហ្មទណ្ឌ ឬជំលោះបោះឆ្នោតទេ ដោយមិនបានញែកអោយដាច់ស្រលះទេ ។ ដូច្នេះនៅក្នុងក្របខ័ណ្ឌច្បាប់សន្មតថា មានតែតុលាការស៊ីវិលគ្រប់ជាន់ថ្នាក់ជាអ្នកដោះស្រាយវិវាទដែលមានចរិតព្រហ្មទណ្ឌ ។ ប៉ុន្តែដោយគ្មានតុលាការដោះស្រាយវិវាទសមត្ថកិច្ច តើ គ.ជ.ប មានការប្រមូលធនធានគំនិតយ៉ាងម៉េចខ្លះ, តើច្បាប់អ្វីខ្លះដែលត្រូវយកមកប្រើប្រាស់?

**ឯកឧត្តម ទុំ ឥន្ទមុនី អភិបាលរងទី ៣ ខេត្តស្វាយរៀង:** មានប្រសាសន៍លើពីរចំណុចទាក់ទងនឹងប្រសាសន៍ឯកឧត្តម **ទេព នីថា** ។ លោកបញ្ជាក់ថា អាជ្ញាធរបានធ្វើការសហការជាមួយ គជប ជានិច្ច អស់បីអាណត្តិទៅហើយ ដើម្បីរក្សាសន្តិសុខ និងសណ្តាប់ធ្នាប់ ។ តើ គ.ជ.ប ចង់អោយអាជ្ញាធរមូលដ្ឋានផ្តល់ការសហការអ្វីទៀត តើមានភារកិច្ចអ្វីទៀត ដើម្បីអោយមានការសហការល្អ? ទាក់ទិនបញ្ហាមេភូមិ អាជ្ញារធរខេត្ត តែងចង់អោយមេភូមិជួយណែនាំប្រជាជនអោយទៅបោះឆ្នោត តែមិនបានបង្គាប់អោយមេភូមិចូលក្នុងមណ្ឌលបោះឆ្នោតទេ ។ បើមានករណីនេះកើតឡើង វាជាការទទួលខុសត្រូវ PEC ហើយបើត្រូវចោទប្រកាន់មេភូមិ សូមអោយមានឈ្មោះច្បាស់លាស់ ។ ចំណុចទី ២ គឺអំពីស្មៀនឃុំមានតែម្នាក់ ហើយគាត់ធ្វើកិច្ចការច្រើនណាស់ ហើយពេលខ្លះរវល់ផង ។ បើគាត់ធ្វើកិច្ចការមិនទាន់ តើ គ.ជ.ប និងក្រសួងមហាផ្ទៃ គួរមានវិធានការបន្ថែមមនុស្សអោយជួយធ្វើកិច្ចការនេះដែរឬទេ?

**ឯកឧត្តម សុខ ផេង សមាជិករដ្ឋសភាមកពីគណបក្ស សម រង្ស៊ី** លើកឡើងលោកមានការភ្ញាក់ផ្អើល ដោយមានសំលេងពីគណបក្សពីរ តែមិនទាន់មានសំលេងពីគណបក្ស សម រង្ស៊ី ក្នុងការពិភាក្សានៃអង្គសន្និសីទ ។ ឯកឧត្តមមានការចាប់អារម្មណ៍ ដោយគាំទ្រមតិរបស់អភិបាលរងខេត្តស្វាយរៀង អំពីបញ្ហាដែលថា មេភូមិចូលទៅមណ្ឌលបោះឆ្នោត ។ នេះដោយសារការមិនគោរពច្បាប់របស់អាជ្ញាធរ និង គ.ជ.ប តែម្តង ។ ឯកឧត្តមបន្ថែមថា នៅខេត្តកំពង់ធំ មិនត្រឹមតែមេភូមិទេ គឺមានដល់អភិបាលរងស្រុកផង បានចូលទៅចាត់ចែងនៅក្នុងការិយាល័យចុះឈ្មោះបោះឆ្នោត ឯនៅពេលបោះឆ្នោតមានរហូតដល់អភិបាលរងខេត្ត ។ ច្បាប់បានចែងអំពីការហាមឃាត់ភ្នាក់ងារយោធា នគរបាល ពុទ្ធបិតសាសនាពីសកម្មភាពទាំងនេះ តែនៅស្រុកប្រសាទសំបូរ អធិការរងប៉ូលីសស្រុក បានចូលរួមក្នុងការឃោសនាបោះឆ្នោត ។ ការបំពានច្បាប់ទាំងនេះ ហើយដែលនាំអោយមានទំនាស់ ។ ឯមន្ត្រីផ្ទៃករដ្ឋបាលខ្លះ បានសុំឈប់ពិសេសដើម្បីចូលរួមឃោសនា ។ ឯកឧត្តមសួរថាតើទង្វើទាំងនេះមានភាពសុចរិត និងយុត្តិធម៌ដែរឬទេ? ឯកឧត្តម បានលើកឡើងថែមទៀតថា គណបក្សសម រង្ស៊ី ធ្លាប់ដាក់ពាក្យបណ្តឹងជាច្រើនតែ PEC ហាក់រារាំងមិនចង់ទទួលបណ្តឹងទាំងនេះ ហើយបើទទួលលុះត្រាតែមានអន្តរាគមន៍ពីថ្នាក់លើរបស់គណបក្ស ហើយជួនកាលគេសួររកភស្តុតាងនៃការប្តឹងនៅពេលដាក់ពាក្យនោះតែម្តង ។ មួយទៀត ឯកឧត្តមបានគាំទ្រមតិរបស់សង្គមស៊ីវិល ដែលត្អូញត្អែរពីសមាសភាពរបស់ គ.ជ.ប ។ ឯកឧត្តមកត់សំគាល់ថា សមាសភាព គ.ជ.ប ស្ថិតក្រោមសំពាធនយោបាយ ។ តាមការសង្កេត សមាជិកខ្លះបានចូលទៅរដ្ឋាភិបាលវិញភ្លាម ក្រោយពេលចប់ការងារជាមួយ គ.ជ.ប ។ ក្រៅពីនេះ ឯកឧត្តមបាននិយាយដល់ការដែលមន្ត្រីគណបក្សយកទ្រព្យសម្បត្តិរដ្ឋ (ដូចជារថយន្ត ហើយទាំងនេះ លោកមានភស្តុតាង) និងពេលវេលារដ្ឋទៅធ្វើការឃោសនាបោះឆ្នោត ។ ទោះបីជាមានការដាក់ពាក្យប្តឹងពីបញ្ហានេះ ក៏មិនមានឃើញការដាក់ពិន័យដែរ ។ លោកចោទសួរថាបើ គ.ជ.ប ទទួលស្គាល់បញ្ហា ដូចជា បញ្ហាក្នុងការបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ឆ្នាំ២០០២ ហើយដែលបញ្ហាដដែលនោះ កើតមានជាថ្មីក្នុងពេលបោះឆ្នោតជាតិឆ្នាំ២០០៣ តើ គ.ជ.ប ហ៊ានសន្យាទេថា បញ្ហា ដដែលនោះឈប់កើតមានទៀត?

នៅចុងបញ្ចប់នៃសំណួររបស់ឯកឧត្តម **សុខ ផេង** លោក **ឱក សេរី សោភ័ក្តិ** បានរំលឹកថា គណបក្ស សម រង្ស៊ី ពិតជាមានសំលេងក្នុងសន្និសីទនេះ ព្រោះលោក **ឡា ដាវុឌ្ឍ** ទីប្រឹក្សាគណបក្សសម រង្ស៊ី នឹងត្រូវមានប្រសាសន៍ក្នុងក្រុមពិភាក្សាទីពីរ ។

លោក **គឹម សុង** មកពីសមាគមការពារសិទ្ធិមនុស្សខ្មែរកម្ពុជាក្រោម បានសួរឯកឧត្តម **អ៊ឹម សូស្តី** ថា លោកធ្លាប់លឺថា មានការផ្សព្វផ្សាយលទ្ធផលបោះឆ្នោតមុនពេលចប់ការបោះឆ្នោត ។ តើរឿងនេះពិតដែរឬទេ ហើយបើមាន តើនេះជាបញ្ហាដែរឬទេ?

## ចំលើយ

ឯកឧត្តម **ទេព នីថា** ឆ្លើយតបទៅនឹងសំណួរមួយចំនួនដូចតទៅ:

- ការដកថយរបស់អង្គការសង្គមស៊ីវិលពីការសង្កេតការបោះឆ្នោតព្រឹទ្ធសភា គឺជាការគួរអោយសោកស្តាយណាស់ ព្រោះពួកគេគឺជាដៃគូដ៏ល្អ ធ្លាប់បានធ្វើការរួមគ្នាដើម្បីបង្ហាញនូវចំណុចខ្វះខាត និងរួមគ្នាដោះស្រាយ ។ បើនិយាយផ្អែកលើមូលដ្ឋានច្បាប់ សង្គមស៊ីវិលអាចចូលរួមក៏បាន មិនចូលក៏បាន ។
- ទាក់ទងនឹងការដោះស្រាយទំនាស់នៃការបោះឆ្នោត: ច្បាប់បោះឆ្នោតជ្រើសរើសតំណាងរាស្ត្រ និងបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ ចែងអំពីការប្រគល់ភារកិច្ចអោយ គ.ជ.ប ដោះស្រាយទំនាស់បោះឆ្នោត ហើយការដោះស្រាយនេះ គឺដាច់ដោយឡែកពីសមត្ថកិច្ចរបស់តុលាការធម្មតា ។
- ឯកឧត្តម **ទេព នីថា** បានអរគុណដល់អាជ្ញាធរខេត្តដែលកន្លងមកបានផ្តល់កិច្ចសហការល្អ ។ អ្វីដែលត្រូវពង្រឹង គឺតួនាទី និងភារកិច្ចនៃស្ថាប័នដែលពាក់ព័ន្ធនឹងការបោះឆ្នោត ។ គ.ជ.ប ម្នាក់ឯងមិនអាចធ្វើកិច្ចការទាំងអស់បានទេ ។ ហេតុនេះហើយបានជាមានការធ្វើប្រតិភូកម្មទៅអោយក្រុមប្រឹក្សាឃុំ-សង្កាត់ លើការចុះឈ្មោះអ្នកបោះឆ្នោត ។
- លោកដឹងថា ស្មៀនឃុំ-សង្កាត់ មមាញឹកណាស់ ដោយធ្វើការចុះបញ្ជីអត្រានុកូលដ្ឋានផង និងចុះឈ្មោះអ្នកបោះឆ្នោតផង ។ ហេតុនេះហើយទើប គ.ជ.ប ពិគ្រោះជាមួយក្រសួងមហាផ្ទៃ បំបែកការិយាល័យជាពីរ ដើម្បីអោយអ្នកមកចុះបញ្ជីអត្រានុកូលដ្ឋាន អាចចុះឈ្មោះបោះឆ្នោតផង ។ ការសុំអោយមានជំនួយការស្មៀនម្នាក់នោះ គឺអាចធ្វើបានតែពេលបោះឆ្នោតប៉ុណ្ណោះ ព្រោះត្រូវការចំណាយច្រើនពេក ។ នៅឆ្នាំ២០០៤ ប្រាក់ចំនួន ៩២ម៉ឺនដុល្លារអាមេរិក ត្រូវបានចំណាយសំរាប់ការចុះឈ្មោះអ្នកបោះឆ្នោត ហើយនៅឆ្នាំ២០០៥ គ្រោងនឹងចំណាយ ៦៦ម៉ឺនដុល្លារ ។ វិធីមួយដែលបន្ធូរបន្ថយការងារ គឺអោយស្មៀនឃុំ-សង្កាត់ ធ្វើការតាំងពីខែមករារហូតទៅ ដើម្បីជៀសវាងការងារគំហុកនៅខែតុលា
- ទាក់ទងនឹងបញ្ហាមេភូមិ ឯកឧត្តមមានប្រសាសន៍ថា គ.ជ.ប និងក្រសួងមហាផ្ទៃ បានចេញសេចក្តីណែនាំដល់ពួកគេកុំអោយទៅជិតមណ្ឌលបោះឆ្នោត ក្រៅពីទៅបោះឆ្នោត ។ តែនេះនៅមានការលំបាក ព្រោះមេភូមិត្រូវបានពឹងពាក់អោយជួយផ្សព្វផ្សាយដល់ប្រជាជនអោយទៅបោះឆ្នោត ។ កន្លងមក មានទំនាស់អំពីបញ្ហានេះមែន តែក៏ត្រូវបានដោះស្រាយហើយដែរ ។
- តាមគណបក្សសម រង្ស៊ី ដែលបានសុំអោយពង្រឹងស្ថាប័ននោះ គឺមិនត្រូវពង្រឹងតែ គ.ជ.ប ទេ តែត្រូវពង្រឹងស្ថាប័នផ្សេងទៀត រួមទាំងគណបក្សនយោបាយផងដែរ ។ ទាក់ទងនឹងការដែលថា គ.ជ.ប មិនទទួលពាក្យបណ្តឹងនោះ គឺមិនដូច្នេះទេ ។ នៅឆ្នាំ២០០៣ គ.ជ.ប បានទទួលបណ្តឹងជាង ២០០០ ។ ឥលូវនេះ គ.ជ.ប កំពុងរៀបចំសេចក្តីព្រាងនីតិវិធីបោះឆ្នោតព្រឹទ្ធសភា ដែលក្នុងនោះ ក៏មាននីតិវិធីទទួល និងដោះស្រាយបណ្តឹងផងដែរ ។

ឯកឧត្តម **អ៊ឹម សូស្តី** ឆ្លើយតបទៅនឹងសំណួរដែលសួរអំពីការប្រកាសលទ្ធផលបោះឆ្នោត ។ លោកថា កាលពីឆ្នាំ១៩៩៨ គ.ជ.ប ត្រូវរង់ចាំលទ្ធផលដែលគេបូក និងបញ្ជូនពីឃុំទៅខេត្ត រួចទើបបញ្ជូនមកដល់ថ្នាក់ជាតិ ដែលនេះត្រូវចំណាយពេលបីបួនថ្ងៃ ។ ឯគណបក្ស និងអង្គការសង្គមស៊ីវិល គេអាចបញ្ជូនលទ្ធផលតាមទូរស័ព្ទ ឬវិទ្យុទាក់ទង តែនេះមិនផ្លូវការឡើយ ។ នៅឆ្នាំ២០០២ គ.ជ.ប ប្តូរវិធីប្រមូល

លទ្ធផល ដោយអោយមណ្ឌលបោះឆ្នោតធ្វើការប្រកួតប្រជែងបូកសរុបលទ្ធផលទាំងយប់ ដើម្បីទទួលបានលទ្ធផលឆាប់ ហើយនៅឆ្នាំ២០០៣ ក៏បានធ្វើដូច្នេះដែរ ។ តែទោះជាយ៉ាងណាក្តី គណបក្ស និងអង្គការសង្គមស៊ីវិលនៅតែអាចប្រកាសមុនតែមិនផ្លូវការ ចំណែក គ.ជ.ប ត្រូវតែរង់ចាំលទ្ធផលច្បាស់លាស់ដែលបញ្ជូនតាមទូរសារ និងមានចុះហត្ថលេខា ។

**លោក គល់ បញ្ញា** ឆ្លើយតបទៅនឹងចំណុចមួយចំនួនដូចខាងក្រោម:

- ជាប្រការមួយ៉ាងដែរ ដែលសភាជាតិមានច្បាប់បោះឆ្នោតព្រឹទ្ធសភា ដែលយកតាមប្រព័ន្ធអសកលនោះ ។ តែប្រព័ន្ធនេះមានបញ្ហា ដោយសារក្របខ័ណ្ឌច្បាប់នេះ មិនមានតម្លាភាព មិនមានយុត្តិធមិ និងគ្មានលក្ខណៈប្រកួតប្រជែង ព្រោះគណបក្សបោះឆ្នោតអោយគណបក្ស វាគ្មានន័យអ្វីទេ ។ បើបោះឆ្នោតអោយបុគ្គលក្នុងគណបក្ស នោះវាប្រសើរបន្តិច ។ បើមានការបង្ហាញអោយច្បាស់អំពីមូលហេតុដែលគណបក្ស ក បោះឆ្នោតអោយគណបក្ស ខ នោះទើបអាចទទួលយកបានខ្លះ ។ អ្វីដែលល្អពីប្រព័ន្ធនេះ គឺការបន្ថែមតំលៃអោយសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ដែលជាអង្គមួយនៃការបោះឆ្នោតព្រឹទ្ធសភា ។
- ទាក់ទងនឹងការផ្សព្វផ្សាយលទ្ធផលឆ្នោត លោកត្អូញត្អែរថា មានគណបក្សមួយដែលមានអំណាច យកលទ្ធផលឆ្នោតមិនផ្លូវការទៅផ្សព្វផ្សាយតាមទូរទស្សន៍ជាតិ ។
- តួនាទីរបស់មេភូមិ គឺសំខាន់ណាស់ ។ បើប្រើប្រាស់ពួកគាត់បានសមស្របគឺមានប្រយោជន៍ណាស់ ដូចដែលត្រូវបានបង្ហាញតាមការសិក្សាស្រាវជ្រាវរបស់មូលនីធិអាស៊ី ។ តែពួកគាត់មិនសូវអព្យាក្រឹត្យទេ ព្រោះត្រូវបានចាត់តាំងដោយគណបក្ស ។

## *ក្រុមឧទ្ទេសនាមទី ២*

១. លោកជំទាវ **ប៉ុក ណណ្ណា**

**នាយកប្រតិបត្តិអង្គការចំរើនស្រ្តី**

លោកជំទាវ **ប៉ុក ណណ្ណា** មានប្រសាសន៍ដោយកត់សំគាល់ថា កម្ពុជាមានទំលាប់មួយ គឺក្រោយការបោះឆ្នោត គណបក្សនយោបាយច្រើនបន្តការប្រឈមមុខគ្នា ដែលនាំអោយមានការអូសបន្លាយដល់ការបង្កើតរដ្ឋាភិបាលថ្មី ។ ដើម្បីដោះស្រាយភាពទ័លច្រកនេះ គឺគេនាំគ្នាបង្កើតស្ថាប័នថ្មី ច្បាប់ថ្មី និងពង្រីកបន្ថែមនូវតួនាទី ដែលទង្វើនេះ មានប្រយោជន៍ដល់គណបក្ស ជាជាងដល់ប្រជាជន ។ អ្នកស្រីបន្ថែមថា បើទោះបីរដ្ឋធម្មនុញ្ញ និងច្បាប់នានា បានចែងពីសិទ្ធិស្មើភាពគ្នារវាងបុរស និងស្រ្តី ក្នុងដំណើរការបោះឆ្នោតក៏ដោយ ក៏ការពិត ចំនួនស្រ្តីដែលជាប់ឆ្នោត ឬទទួលការតែងតាំង មិនសមាមាត្រនឹងចំនួនស្រ្តីដែលចូលរួមបោះឆ្នោតឡើយ ។ នេះបង្ហាញពីកង្វះយន្តការ និងឆន្ទៈពីរដ្ឋាភិបាល និងថ្នាក់ដឹកនាំគណបក្ស ក្នុងការជំរុញអោយមានសមភាព និងសមធមិយេនឌ័រ ។ លោកជំទាវ បានផ្តល់ជាតួលេខថា នៅឆ្នាំ១៩៩៣ មានស្រ្តីតែ ៥ នាក់ប៉ុណ្ណោះដែលជាប់ឆ្នោត ក្នុងចំណោមអាសនៈចំនួន ១២០អាសនៈក្នុងសភា ហើយនៅឆ្នាំ១៩៩៨ មានបេក្ខភាពស្រ្តីចំនួន ១៦,៩១% និងមានស្រ្តី ៧នាក់ ជាប់ឆ្នោត ក្នុងចំណោមអាសនៈចំនួន ១២២ ឯនៅឆ្នាំ២០០៣ មានបេក្ខភាពស្រ្តីចំនួន ២៥,៨៨% និងមានស្រ្តី ១៥នាក់ជាប់ឆ្នោត ក្នុងចំណោមអាសនៈចំនួន ១២៣ ។

លោកជំទាវបានគូសបញ្ជាក់នូវបញ្ហាជាក់លាក់មួយចំនួន ដូចជា: បេក្ខភាពស្រ្តីឈរឈ្មោះមានចំនួនតិច សមាសភាពស្រ្តីជាសមាជិក គ.ជ.ប គ្រប់លំដាប់ថ្នាក់ មានចំនួនតិច អំពើហិង្សា ការគំរាមកំហែង និងឃាដកម្ម ដំណើរការចុះឈ្មោះអ្នកបោះឆ្នោត មិនមានលក្ខណៈងាយស្រួល នីតិវិធីចុះឈ្មោះ និងការពិនិត្យបញ្ជីឈ្មោះ មានលក្ខណៈស្មុគស្មាញ ការបណ្តុះបណ្តាលបេក្ខភាពនារី និងអ្នកសង្កេតការណ៍ស្រ្តីនៅមានកំរិត ការយឺតយ៉ាវក្នុងការចេញអត្តសញ្ញាណប័ណ្ណ និងការផ្សព្វផ្សាយពីការបោះឆ្នោតនៅមានកំរិត ។

ដើម្បីដោះស្រាយនូវបញ្ហាទាំងនេះ លោកជំទាវ មានអនុសាសន៍ដូចតទៅ:

- គួរកំណត់បេក្ខភាពស្រ្តីអោយច្បាស់ក្នុងគោលនយោបាយបក្ស និងក្នុងច្បាប់បោះឆ្នោត

- ចាត់វិធានការណ៍ពិសេសអោយមានស្ត្រីចូលរួមគ្រប់លំដាប់ថ្នាក់នៃការរៀបចំការបោះឆ្នោត
- ធានាអោយខាងតែបាននូវសុវត្ថិភាពបេក្ខជន និងបេក្ខនារី ព្រមទាំងសកម្មជននយោបាយ
- គ.ជ.ប មិនត្រូវសំរបសំរួលករណីពុករលួយក្នុងដំណើរការបោះឆ្នោតទេ
- ផ្តល់ការបណ្តុះបណ្តាលអោយបានទូលំទូលាយដើម្បីលើកទឹកចិត្តស្ត្រីអោយអនុវត្តសិទ្ធិស្របច្បាប់របស់ខ្លួន
- ផ្តល់អត្តសញ្ញាណប័នអោយបានឆាប់ និងគ្រប់ៗគ្នា
- ផ្សព្វផ្សាយអោយបានទូលំទូលាយអំពីសារៈប្រយោជន៍នៃការបោះឆ្នោត
- នៅចុងបញ្ចប់ លោកជំទាវសង្កត់ធ្ងន់ថា ការចូលរួមបានច្រើនពីសំណាក់ស្ត្រីក្នុងដំណើរការសំរេចចិត្ត នឹងនាំអោយមានការរីកចំរើននូវលទ្ធិប្រជាធិបតេយ្យ ដែលនេះជាកត្តាសំខាន់សំរាប់ជួយកាត់បន្ថយទំនាស់ ។

២. លោក **ឡា ជាវុឌ្ឍ**

**ទីប្រឹក្សាគណបក្ស សម រង្ស៊ី**

លោក **ឡា ជាវុឌ្ឍ** បានសំដែងនូវការពេញចិត្តចំពោះខប់សែលដំណាក់កាលទី ១ ។ លោកបានបញ្ជាក់ថា ការបោះឆ្នោតជាតិឆ្នាំ២០០៣ បានបញ្ចប់ទៅដោយការច្របូកច្របល់ ហើយបន្ទាប់មកលោកសំដែងការគាប់ចិត្ត និងលើកទឹកចិត្តដល់ខប់សែលដំណាក់កាលទី ២ ទៀត ព្រោះ ខប់សែលជា "យន្តការនិយាយគ្នាមុនដើម្បីជៀសវាងទំនាស់នៅពេលក្រោយ" ។ នេះជាទំលាប់ ឬជាឥរិយាបថជនស៊ីវិល័យថ្លៃថ្នូរ និងមានគំនិតប្រជាធិបតេយ្យខ្ពស់ ។

លោកបន្តថា ដោយសារខប់សែលថ្លៃថ្នូរបែបនេះហើយ ទើបលោកសុំអោយ ខប់សែល **កុំពាក់ព័ន្ធនឹង**ការបោះឆ្នោតព្រឹទ្ធសភាខាងមុខ ព្រោះច្បាប់នៃការបោះឆ្នោតព្រឹទ្ធសភានេះ អាចធ្វើអោយគេដឹងពីលទ្ធផលមុនផង និងរារាំងមិនអោយគណបក្សស្របច្បាប់ផ្សេងទៀតដែលពុំមានអាសនៈក្នុងសភា ឬគ្មានសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់ ពុំអាចចូលរួមបានផង ។ លោកបន្តថា "ការបោះឆ្នោតបែបនេះគឺជារឿងស្មោគគ្រោក ដែលពុំគួរយកខ្លួនទៅបៀតទាល់តែសោះ!" ។

លោកផ្តល់ការគាំទ្រជាពិសេសដល់រចនាសម្ព័ន្ធទី ៥ របស់ខប់សែលដំណាក់កាលទី ២ គឺការផ្សព្វផ្សាយតាមសារពត៌មាន តែសុំកុំអោយធ្វើកៀកនឹងការបោះឆ្នោតឆ្នាំ២០០៨ ពេក ព្រោះបើនិយាយ ក៏ពុំមានឱកាសនឹងកែប្រែអ្វីដែរ ។ លោកក៏សុំអោយមានការផ្សព្វផ្សាយតាមរលកធាតុអាកាសនូវរាល់កិច្ចប្រជុំ ខប់សែល ។ លោកបន្តថា បើ ខប់សែលដំណាក់កាលទី ១ ធ្វើដូច្នេះ ម្ល៉េះសមឯកឧត្តម **អ៊ឹម សួស្តី** ប្រធាន គ.ជ.ប មិនហ៊ានបដិសេធសំណើរបស់គណបក្ស សម រង្ស៊ី ដែលសុំទិញបញ្ជីបោះឆ្នោតដំបូងនោះឡើយ ហើយ ឯកឧត្តម **ទេព នីថា** ក៏ប្រហែលមិនហ៊ាននិយាយថា "គ្មានគោលការណ៍លក់បញ្ជីបោះឆ្នោតដំបូង" នោះដែរ ។ លោកបានបន្ថែមថា ទង្វើបែបនេះរបស់ គ.ជ.ប ជាការបំពានទាំងស្រុងលើមាត្រា ៦៣ ថ្មី ក៏ដូចជាចំណុច ៦.២៤.២ និង ៦.២៤.៥ នៃច្បាប់ជ្រើសរើសតំណាងរាស្ត្រ និងលើបទបញ្ជា និងនីតិវិធីរបស់ គ.ជ.ប ហើយជាលទ្ធផលបានធ្វើអោយមនុស្សជាងមួយលាននាក់ដែលបានចុះឈ្មោះ ហើយវង្វេងការិយាល័យបោះឆ្នោត ។ លោកបានជំរាបអង្គសន្និសីទថា ការបោះឆ្នោតឆ្នាំ១៩៩៣ ដែលគ្រប់គ្រងដោយអ៊ុនតាក់នោះ ពុំមានលទ្ធភាពលួចបន្លំសន្លឹកឆ្នោតទេ តែមានការគំរាម និងសំលាប់ ។ ការបោះឆ្នោតឆ្នាំ១៩៩៨ និង ២០០៣ ដែលគ្រប់គ្រងដោយ គ.ជ.ប មានលទ្ធភាពលួចបន្លំ និងទិញសន្លឹកឆ្នោត ការលួចតាមការធ្វើច្បាប់ និងបំពានច្បាប់ដែលមានលក្ខណៈជាយុទ្ធសាស្ត្រ ។ ឯការបោះឆ្នោតឆ្នាំ២០០៦ គេនឹងមានលទ្ធភាពលួចបន្លំទៀត គឺលួចទាំងស្រុងតាមការធ្វើច្បាប់ ហើយមិនចាំបាច់គំរាម និងសំលាប់ទេ ។ លោកចោទសួរថា ចុះការបោះឆ្នោតឆ្នាំ២០០៨ នឹងទៅជាយ៉ាងណាទៅ? លោកបន្ថែមថា សព្វថ្ងៃពុំមានតួអង្គណាមួយចាត់វិធាន ការទប់ស្កាត់ការលួចសន្លឹកឆ្នោតស្រស់ៗតាមលក្ខណៈបច្ចេកទេស និងតាមការធ្វើច្បាប់ដូច្នេះឡើយ ។ ចុងបញ្ចប់ លោកសួរថា "តើយើងទាំងអស់គ្នា ពិសេសបំផុត UNDP និងយន្តការខប់សែល មានវិធានការអ្វីសំរាប់

ទប់ស្កាត់ កុំអោយគេអាចបន្ថយកសកម្មភាពដ៏បរិសុទ្ធរបស់ខ្លួន ទៅធ្វើជាឧបករណ៍សំរាប់សម្របច្បាប់អោយគេ ក្នុងការបោះឆ្នោតខាងមុខនេះបានទៀត?"

### ៣. ឧត្តមសេនីយ៍ត្រី **សាវ៉ាន គំសត់**

### ប្រធានមន្ទីរចាត់ការនៃសាលាភូមិន្ទនគរបាលនៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ

ក្នុងនាមកងកំលាំងនគរបាលជាតិ លោកឧត្តមសេនីយ៍មានប្រសាសន៍ លោកមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដែល ត្រូវបានអញ្ជើញអោយចូលរួមក្នុងសន្និសីទនេះ ហើយសូមជូនពរ និងលើកទឹកចិត្តដល់ដំណើរការនេះ ។ កងកំលាំងនគរបាលជាតិតែងទទួលសំណូមពរពី គ.ជ.ប អោយជួយផ្តល់ការការពារសន្តិសុខ សុវត្ថិភាព និងរក្សាសណ្តាប់ធ្នាប់ គ្រប់ការបោះឆ្នោត ហើយកងកំលាំងប៉ូលីសតែងបានធ្វើការដោយអព្យាក្រឹត្យ មិនលំអៀងទៅបុគ្គល ឬគណបក្សណាមួយឡើយ ។ លោកមិនព្យាយាមព្យាករណ៍ពីលទ្ធភាពទំនាស់ក្នុងពេលបោះឆ្នោតទេ តែបានផ្តោតលើសកម្មភាព ដែលកំលាំងនគរបាលជាតិត្រូវធ្វើនៅពេលបោះឆ្នោត ។ នៅគ្រប់ពេលបោះឆ្នោត កងកំលាំងនគរបាលជាតិដែលមានភារកិច្ចធានាសន្តិសុខ គឺស្ថិតក្រោមការបញ្ជាផ្ទាល់ពី គ.ជ.ប ដោយ គ.ជ.ប ចេញសេចក្តីសំរេចបង្កើតអនុគណៈកម្មការសន្តិសុខអចិន្ត្រៃយ៍មួយនៅភ្នំពេញ ។ ដោយមានសេចក្តីសំរេចនេះ នគរបាលជាតិរៀបចំ អោយមាន ៤អនុគណៈកម្មការ ដោយផ្អែកលើច្បាប់បោះឆ្នោត និងក្រមសីលធម៌នៃកងកំលាំងនគរបាលជាតិ ក្នុងនោះ នៅថ្នាក់ជាតិមានអនុគណៈកម្មការអចិន្ត្រៃយ៍សន្តិសុខនៅថ្នាក់ខេត្ត-ក្រុង មានការិយាល័យសន្តិសុខខេត្ត-ក្រុង នៅស្រុកមានការិយាល័យសន្តិសុខស្រុក-ខណ្ឌ និងនៅឃុំ-សង្កាត់ មានការិយាល័យសន្តិសុខឃុំ-សង្កាត់ ។ នៅតាមមណ្ឌលបោះឆ្នោតនីមួយៗ មានមន្ត្រីសន្តិសុខ ៥នាក់ស្លៀកពាក់ស៊ីវិល ដែលក្នុងនោះ ២នាក់នៅក្នុងការិយាល័យបោះឆ្នោត និង ៣នាក់ ទៀតក្នុង ២០០ម៉ែត្រនៃការិយាល័យបោះឆ្នោត ។ ក្នុងចំណោមទាំង ៥នាក់ មានអាវុធមួយដើមដោយមិនបញ្ចេញអោយឃើញ ដើម្បីជៀស វាងការភ័យខ្លាច ។

នៅពេលបោះឆ្នោត កងកំលាំងនេះ ត្រូវការការពារសន្តិសុខ សុវត្ថិភាពដល់បេក្ខជនឈរឈ្មោះ ឃោសនិក មន្ត្រីសង្កេតការណ៍ជាតិ និងអន្តរជាតិ មន្ត្រី គ.ជ.ប និងអ្នកបោះឆ្នោតទាំងពីរភេទ ។ រីឯទីកន្លែងត្រូវការពារ រួមមាន ការិយាល័យបោះឆ្នោត ស្នាក់ការគណបក្ស ការិយាល័យចុះឈ្មោះ កន្លែងរក្សាហិបឆ្នោត និងការិយាល័យសន្លឹកឆ្នោត ។ តាមបទពិសោធន៍កន្លងមក ការចាត់ចែងនេះបានផ្តល់សន្តិសុខ និងសុវត្ថិភាពល្អដល់ការបោះឆ្នោត និងទទួលបានការវាយតំលៃខ្ពស់ពីមហាជន និងមតិជាតិ និងអន្តរជាតិ ។ សំរាប់សកម្មភាពទាំងនេះ កងកំលាំងនគរបាល បានទទួលការឧបត្ថម្ភទាំងសំភារៈ និងថវិកាពី គ.ជ.ប ហើយស្ថិតក្រោមការបញ្ជាពី គ.ជ.ប ។ អនុគណៈកម្មការតែងណែនាំជាប្រចាំដល់មន្ត្រីសន្តិសុខអោយប្រកាន់ខ្ជាប់តាមច្បាប់ និងក្រមសីលធម៌ ។ តែបើមានការបំពានណាមួយនៅគណៈកម្មការរៀបចំការបោះឆ្នោតនៅឃុំ-សង្កាត់ នឹងរៀបចំពាក្យបណ្តឹង ហើយនិងការស៊ើបអង្កេត ។ ពាក្យបណ្តឹងនឹងបញ្ជូនតាម គ.ជ.ប មកស្នងការនគរបាលជាតិ ដើម្បីពិនិត្យ និងដាក់ពិន័យតាមករណីជាក់ស្តែង ។ បើទោះបីមានការខ្វះខាតខ្លះ លោកឧត្តមសេនីយ៍ត្រី ក្នុងនាមឯកឧត្តមអគ្គស្នងការនគរបាលជាតិ និងកងកំលាំងនគរបាលជាតិ សូមសន្យាបន្តផ្តល់ការការពារសន្តិសុខអោយបានល្អប្រសើរក្នុងពេលបោះឆ្នោតខាងមុខៗទៀត ។

### ៤. លោកបណ្ឌិត **ហង្ស ពុន្ធា**

### នាយកប្រតិបត្តិអង្គការនិចហ្វិក

បន្ទាប់ពីលោកបណ្ឌិតបាននែនាំពីស្ថាប័នរបស់លោក ដែលធ្វើការពាក់ព័ន្ធនិងការងារបោះឆ្នោតកន្លងទៅ លោកបណ្ឌិតបានកត់សំគាល់ឃើញថា រាល់ការបោះឆ្នោតទាំងអស់សុទ្ធតែមានទំនាស់ ដែលទាមទាអោយមានយន្តការមួយសំរាប់ដោះស្រាយ ហើយយន្តការខប់សែលបានធ្វើរួចមកហើយ ។ លោកបណ្ឌិត ក៏បានកត់សំគាល់ផងដែរថា លទ្ធផលការបោះឆ្នោតកន្លងមកនេះមានលក្ខណៈត្រឹមត្រូវ អាចទទួលយកបានប៉ុណ្ណោះ ដែលចំណុចនេះទាមទារអោយមានការជំរុញឆ្ពោះទៅរកលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងមានតំលាភាព ។ លោកបណ្ឌិតបានលើកឡើងពីប្រភពនៃទំនាស់នៅពេលបោះឆ្នោតច្រើនតែបណ្តាលមកឬសគល់បីធំៗគឺ:

- **ប្រព័ន្ធច្បាប់** ដែលពិសេសទាក់ទងទៅនិង រដ្ឋធម្មនុញ្ញមិនបានចែងអោយ គ.ជ.ប ជាស្ថាប័នធម្មនុញ្ញ ការអនុវត្តន៍យកប្រព័ន្ធបោះឆ្នោតសមាមាត្ររូបមន្តបែងចែកអាសនៈ មិនផ្តល់លទ្ធភាពអ្នកដែលមាន សំលេងតិច ការកំណត់តួនាទីរបស់ គ.ជ.ប អោយធ្វើជាចុងចោទផង ជាអ្នកជំរះក្តីផង និងជាអ្នកអនុវត្ត ការរៀបចំការបោះឆ្នោតផង មិនមានច្បាប់គ្រប់គ្រាន់ដែលចែងទណ្ឌកម្មនៅក្នុងទោសបញ្ញត្តិ ការបង្កើតអោយមានគណៈកម្មាធិការសម្របសម្រួលអង្គការ (គ.ស) ជាដើម ។
- **យន្តការអនុវត្ត** ការប្រតិបត្តិរបស់ គ.ជ.ប មានការលំអៀង ឬខ្វះបទពិសោធន៍ មានការរិះគន់ថា គ.ជ.ប បង្កើតឡើងដោយកូតារបស់គណបក្ស ការមិនបានផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរទៅអ្នកគ្រប់អាយុ បោះឆ្នោតអោយទាន់ពេល ការខ្វះឆន្ទៈរបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ក្នុងការចុះឈ្មោះអ្នកបោះឆ្នោត ។ល។
- **ចរិតបក្ស ឆន្ទៈបុគ្គល និងចរិតនយោបាយ** លោកបណ្ឌិតសំដៅលើរាល់គណបក្សនៅប្រទេសកម្ពុជា កើតចេញពីប្រភពផ្សេងៗគ្នា ដូចជា សង្គមនិយមរាជានិយម ប្រជាធិបតេយ្យបឋមនិយម... ដែលលក្ខណៈនេះហើយធ្វើអោយមានការប្រកួតប្រជែងគ្នាជាខ្លាំង និងអាចអោយមានការប្រើវិធីផ្សេងៗដើម្បីយកជ័យជំនះលើភាគីម្ខាងៗ ។

ចំពោះនីតិវិធីក្នុងការដោះស្រាយបញ្ហាទាំងអស់នេះ លោកបណ្ឌិតបានលើកជាយុទ្ធសាស្ត្រ ដែលរួមមាន២៣ចំណុច ។ ជាចុងបញ្ចប់ លោកបណ្ឌិតបានស្នើអោយយន្តការខប់សែលអនុវត្តធ្វើ តាំងពីថ្នាក់ជាតិ ថ្នាក់ខេត្ត រហូតដល់ថ្នាក់ឃុំសង្កាត់ និងភូមិ ដើម្បីអោយមានជ្រួតជ្រាបគ្រប់ទីកន្លែង និងធ្វើអោយមានឥទ្ធិពលក្នុងការផ្តល់អនុសាសន៍ដល់ គជប និងស្ថាប័នពាក់ព័ន្ធ ។

## វេទិកាសំណួរចំលើយ

លោកស្រី **ឡុច សុវានី** មកពីអង្គការ និចហ្វិច

- តើមានការគំរាមគំហែងដល់តំណាងស្ត្រីនៅតាមឃុំសង្កាត់ដែរទេ?
- បើមានកើតហេតុការណ៍បែបនេះតើ យើងដោះស្រាយយ៉ាងដូចម្តេច?

ឯកឧត្តម **ឃឹម សិលា** អភិបាលខេត្តស្ទឹងត្រែង បានលើកឡើងពីបញ្ហាបច្ចេកទេសមួយចំនួនសំរាប់ គ.ជ.ប ពិសេសទាក់ទងទៅនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលបិទអោយអ្នកមើលក្នុងរយៈពេលខ្លី ដែលនេះអាចជាបញ្ហាសំរាប់ប្រជាពលរដ្ឋ ហើយឯកឧត្តមបានស្នើអោយ គ.ជ.ប មេត្តាសំរួលយ៉ាងណាអោយបញ្ហានេះ ដោះស្រាយអោយទាន់ពេលវេលា ។

លោកស្រី **យន់ ឡៃ** ជំទប់ទី ២ ឃុំក្បាលកោះ ខេត្តកណ្តាល បានសំណូមពរទៅ គ.ជ.ប លើបីចំណុចដូចជាៈ

- ស្នើអោយមានការចាត់តាំងពី គ.ជ.ប អោយមានសមាសសភាពមកពីគ្រប់គណបក្ស ដែលមានអាសនៈនៅក្រុមប្រឹក្សាឃុំ ដើម្បីចូលរួមជួយការងារចុះឈ្មោះអ្នកបោះឆ្នោត ។
- តើព្រះសង្ឃមានសិទ្ធិនិមន្តទៅបោះឆ្នោតដែរទេ? ដោយសារអ្វី? បើមិនបានដោយសារអ្វី?
- សូមកំណត់អោយបានច្បាស់នូវកូតារបស់ស្ត្រីនៅក្នុងពេលបោះឆ្នោត មិនចំពោះការបោះឆ្នោតមួយណាឡើយ និងស្នើសុំអោយបេក្ខភាពជាស្ត្រីនៅលំដាប់លេខមួយក្នុងបញ្ជី

អ្នកចូលរួមម្នាក់ បានលើកការព្រួយបារម្ភពីការបោះឆ្នោតព្រឹទ្ធសភាខាងមុខដែលអនុញ្ញាតអោយតែសមាជិកសភា និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ប៉ុណ្ណោះ មានសិទ្ធិចូលរួមបោះឆ្នោត និងលោកបានលើកពីបញ្ហាសមាសភាពរបស់ គ.ជ.ប ដែលមានមកតែពីគណបក្សពីរធំៗប៉ុណ្ណោះ និងមិនមានសមាសភាព មកពីគណបក្សប្រឆាំងឡើយ ដែលនេះអាចធ្វើអោយបាត់ទំនុកចិត្តពីប្រជាពលរដ្ឋ និងមហាជន ។

លោកក៏បានលើកពីបញ្ហាប្រធានភូមិថា មានសារៈសំខាន់សំរាប់ការបោះឆ្នោតនីមួយៗ និងស្នើអោយក្រសួងមហាផ្ទៃ ចេញសេចក្ដីណែនាំស្ដីពីការជ្រើសរើសប្រធានភូមិអោយបានឆាប់ និងធានាអោយមានការចូលរួមគ្រប់សមាសភាព មកពីគ្រប់គណបក្សមានអាសនៈនៅសភា ដើម្បីជៀសវាងទំនាស់ដ៏ស្មុចស្រាវដែលអាចកើតមាននៅពេលបោះឆ្នោតនីមួយៗ ។ ម្យ៉ាងទៀត លោកសូមអោយ គ.ជ.ប អនុវត្តអំណាចរបស់ខ្លួនអោយបានស្មើភាព យុត្តិធម៌ចំពោះគ្រប់គណបក្ស កុំអោយមានការប្រកាន់ ឬលំអៀងទៅកាន់គណបក្សណាមួយ ។

## ការសរុបលទ្ធផលសន្និសីទ

លោក **ឌិក សេរី សោភក្ដិ** អ្នកសំរបសំរួលយន្តការ ខបស៊ែល បានធ្វើសេចក្ដីសង្ខេបលទ្ធផលនៃការពិភាក្សា ជូនអង្គសន្និសីទទាំងមូលជ្រាបជាពតិមានដោយលោកលើកបញ្ជាក់ថា លទ្ធផលទទួលបានហួសពីការស្មានរបស់គណៈកម្មការរៀបចំអង្គសន្និសីទ ទាំងការចូលរួម ទាំងការបញ្ចេញមតិយោបល់ និងអនុសាសន៍ ដែលលោកអាចកំណត់បានគោលធំមួយចំនួនដូចតទៅ:

- តាមមតិជាតិ និងអន្តរជាតិបានទទួលស្គាល់ ខបស៊ែល ទី ១ ថា បានបំពេញបេសកម្មរបស់ខ្លួនជាវិជ្ជមាន ដូចនេះហើយបានជាមតិជាតិ និងអន្តរជាតិគាំទ្រអោយមាន ខបស៊ែលនេះឡើងក្នុងតំណាក់កាលទី ២
- លោកស្រី ANNE ISABELLE តំណាងរងរបស់កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ បានគាំទ្រយ៉ាងពេញទំហឹង ចំពោះដំណើរការខបស៊ែលតំណាក់កាលទី ២ នេះ
- តាមមតិវាគ្មិន ការបោះឆ្នោតខាងមុខនេះ នឹងមានបញ្ហាចាក់ស្រេះជាច្រើននៅឡើយគឺតតាំងពីការចុះឈ្មោះបោះឆ្នោត ដំណាក់កាលឃោសនាបោះឆ្នោត ពេលបោះឆ្នោត ថ្ងៃរាប់សន្លឹកឆ្នោត និងដោះស្រាយបណ្ដឹងក្រោយថ្ងៃបោះឆ្នោត
- អង្គសន្និសីទទទួលស្គាល់ការខិតខំប្រឹងប្រែងរបស់ គ.ជ.ប ដើម្បីធ្វើយ៉ាងណាអោយមានដំណោះស្រាយមានជាហូរហែ ក្នុងនោះក៏មានការលើកឡើងថា គ.ជ.ប បានសំរេចជាវិជ្ជមានក្នុងលក្ខណៈបច្ចេកទេសនូវគោលការណ៍នានា ដើម្បីអនុវត្តការរៀបចំការបោះឆ្នោតជាបន្តបន្ទាប់
- បញ្ហាទំនុចចិត្តរបស់សាធារណៈមតិចំពោះ គ.ជ.ប នៅតែជាបញ្ហានៅឡើយ ជាពិសេសសមាសភាព គ.ជ.ប ដែលមានវាគ្មិនខ្លះស្នើសុំអោយការជ្រើសរើសមានលក្ខណៈបើកទូលាយជាងនេះ
- មានមតិខ្លះបានលើកឡើងពីតួនាទីរបស់ក្រសួងមហាផ្ទៃក្នុងការចេញអត្តសញ្ញាណប័ណ្ណជូនប្រជាពលរដ្ឋ និងស្នើសុំអោយក្រសួងធ្វើយ៉ាងណាជួយសំរួលអោយបានឆាប់ ដើម្បីអោយមានការងាយស្រួលក្នុងការចុះឈ្មោះបោះឆ្នោត
- តួនាទីមេភូមិសំរាប់ការបោះឆ្នោតនៅតែជាបញ្ហានៅឡើយសំរាប់អង្គការសង្គមស៊ីវិល ក្នុងនោះយើងមានសង្ឃឹមយ៉ាងមុតមាំថាក្រសួងមហាផ្ទៃ តាមរយៈច្បាប់ នឹងធ្វើការដោះស្រាយអោយបានសមស្របបំផុត
- ជាទូទៅដំណើរការបោះឆ្នោតនៅកម្ពុជាមានភាពរីកចំរើនជាបណ្ដើរៗ យ៉ាងណានោះនៅមាន វាគ្មិនមួយចំនួនបានលើកឡើងថាបរិយាកាសនៃការភ័យខ្លាចនៅពេលបោះឆ្នោតនៅតែកើតមាននៅឡើយ ពិសេសសន្តិសុខរបស់ស្ត្រីភេទ និងមានការលំបាកជាច្រើន ទាំងនៅពេលចុះឈ្មោះ ពេលទៅបោះឆ្នោត និងការឈរឈ្មោះបោះឆ្នោត ដែលនេះទាមទាអោយក្រសួងមហាផ្ទៃ និង គ.ជ.ប ធ្វើការយកចិត្តទុកដាក់ ពិសេសចំពោះបញ្ហានេះ
- ការបោះឆ្នោតព្រឹទ្ធសភានៅខែមករា ឆ្នាំ២០០៦ ខាងមុខនេះ នៅតែជាបញ្ហានៅឡើយ ដោយក្រុមសង្គមស៊ីវិលមួយចំនួន បានប្រកាសជំហររបស់ខ្លួនថា នឹងមិនចូលរួមសង្កេតការនៅក្នុងការបោះឆ្នោតខាងមុខនេះឡើយ ហើយគណបក្សប្រឆាំងបានធ្វើការរិះគន់យ៉ាងខ្លាំងចំពោះដំណើរការរៀបចំនៃការបោះឆ្នោតនេះ

- តំណាងនគរបាលជាតិមានប្រសាសន៍ថានឹងធានាសុវត្ថិភាពជូនប្រជាពលរដ្ឋនៅពេលបោះឆ្នោតខាងមុខ តែនៅមានវាគ្មិនមួយចំនួនទទួលស្គាល់ថា សន្តិសុខនៅពេលបោះឆ្នោតខាងមុខ និងនៅតែជាបញ្ហានៅឡើយ ដែលទាមទាអោយមានការចូលរួមយ៉ាងសកម្មជួយគាំទ្រ និងសហការពី គ.ជ.ប និងភាគីពាក់ព័ន្ធឯទៀតៗ ហើយយើងមានការសប្បាយដោយលឺតំណាងក្រសួងលើកឡើងថា កងកំលាំងសន្តិសុខជាតិ នឹងដាក់នៅក្រោមការបញ្ជារបស់ គ.ជ.ប និងធ្វើការសហការល្អជាមួយ គ.ជ.ប នៅពេលបោះឆ្នោតខាងមុខនេះ ។ យើងសង្ឃឹមថាបើធ្វើយ៉ាងដូចនេះមែន អាចដោះស្រាយបញ្ហាជាច្រើន ។
- ខាង គ.ជ.ប ក៏ទទួលស្គាល់ផងដែរថា នឹងតំរូវអោយមានវគ្គបំពាក់បំប៉នផ្នែកបច្ចេកទេសដល់បុគ្គលិកគ្រប់ជាន់ថ្នាក់តាំងពីថ្នាក់ខេត្ត ឃុំ និងការិយាល័យបោះឆ្នោត និងធ្វើការបំពាក់បំប៉នបន្ថែមទៀតលើផ្នែកមធ្យោបាយ ដើម្បីធ្វើយ៉ាងណាអោយការបោះឆ្នោតប្រព្រឹត្តិទៅដោយរលូន ។

## សន្ទរកថាបិទដោយឯកឧត្តម ព្រុំ សុខា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ

ជាការចាប់ផ្តើម ក្នុងនាមឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្នុងនាមឯកឧត្តមផ្ទាល់ ឯកឧត្តមបានសំដែងនូវសេចក្តីរីករាយដោយឃើញយន្តការខប់សែលដំណាក់កាលទី ២ មានដំណើរការឡើងវិញ ក្រោមការជួយឧបត្ថម្ភពីកម្មវិធីអភិវឌ្ឍន៍របស់អង្គការសហប្រជាជាតិ (UNDP) និងបានសំដែងនូវការគាំទ្រយ៉ាងពេញទំហឹងចំពោះយន្តការខប់សែលទី ២ នេះ ។ ឯកឧត្តមបានធ្វើការកត់សំគាល់ ជាទូទៅចំពោះស្ថានការណ៍បោះឆ្នោតនៅកម្ពុជា ក្នុងនាមឯកឧត្តមធ្លាប់បានចូលរួមយ៉ាងសកម្មថា ដំណើរការបោះឆ្នោតនៅកម្ពុជា មានការកែប្រែឆ្ពោះទៅរកភាពល្អប្រសើយ៉ាងច្រើន និងបានចាក់គ្រឹះយ៉ាងរឹងមាំនៅក្នុងវប្បធម៌នយោបាយសង្គមកម្ពុជាដែលមានរហូតដល់ថ្នាក់មូលដ្ឋានឃុំ-សង្កាត់ទៀត ។

ឯកឧត្តមបានលើកយកទិដ្ឋភាពសំខាន់ៗនៃការបោះឆ្នោតក្នុងរយៈពេល ១២ឆ្នាំកន្លងមកនេះ ដោយបានបង្ហាញពីការវិឌ្ឍន៍ដ៏គួរអោយកត់សំគាល់ទៅរកភាពម្ចាស់ការ និងមានលទ្ធភាពរបស់ខ្លួនក្នុងការរៀបចំការបោះឆ្នោតប្រកបដោយស្តង់ដាបច្ចេកទេសខ្ពស់ ។ ពិសេសចាប់តាំងពីការបោះឆ្នោតនៅឆ្នាំ១៩៩៨ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់ ឆ្នាំ២០០២ និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រឆ្នាំ២០០៣ ។ ក្នុងនោះ ឯកឧត្តមបានលើកឡើងពីការចូលរួមចំណែកយ៉ាងសកម្មពីសំណាក់យន្តការ ខប់សែល ដំណាក់កាលទី ១ ក្នុងការទប់ស្កាត់ទំនាស់ ក៏ដូចជា បង្ការទំនាស់នានា និងការប្រើអំពើហិង្សាបានមួយកំរិត ។ ជោគជ័យកន្លងមកដែលឯកឧត្តមបានលើកជាសេចក្តីសង្ខេបមានដូចជា ការបង្កើតអោយមានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតថ្មី ការផ្តល់លទ្ធភាពអោយមានការចូលរួមពិគ្រោះយោបល់ និងការប្រមូលកំលាំង ការរៀបចំបង្កើតប្រព័ន្ធចុះឈ្មោះអ្នកបោះឆ្នោត អចិន្ត្រៃយ៍ដែលមានការចំណាយថវិកាតិច ការបើកទូលាយអោយមានប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយតាមរយៈប្រព័ន្ធរដ្ឋ ការជំរុញ និងផ្តល់លទ្ធភាពអោយមានអ្នកអង្កេតការណ៍ជាតិ និង អន្តរជាតិអោយបានច្រើន ដើម្បីធានាតំលាភាព និងបង្កើនជំនឿទុកចិត្តដល់សាធារណជន ការចំណាយលើការរៀបចំដំណើរការបោះឆ្នោតមានការថយចុះ បើប្រៀបធៀបទៅការចំណាយលើការបោះឆ្នោតក្នុងពេលមុនៗ និងក្នុងប្រទេសដទៃទៀត ។ ឯកឧត្តមបានបន្តដោយលើកយកពីការដោះស្រាយទំនាស់ដោយផ្អែកលើបទដ្ឋានច្បាប់ និងលើកយកយន្តការផ្សេងៗមកដោះស្រាយ ក្នុងនោះយន្តការខប់សែលបានដើរតួនាទីសំខាន់ក្នុងការរួមចំណែកដ៏មានតំលៃដល់លទ្ធិប្រជាធិបតេយ្យ សន្តិភាព និងការអភិវឌ្ឍន៍នៅកម្ពុជា ។ ការពិតនៃមេរៀននេះ មានភស្តុតាងជាច្រើនហើយនៅក្នុងប្រទេសកម្ពុជា ដែលនៅក្នុងប្រទេសនេះ ការកែប្រែជាបន្តបន្ទាប់លើយន្តការ និងដំណើរការបោះឆ្នោតនៅក្នុងរយៈពេល ១២ឆ្នាំកន្លងមក បានបង្កើនគុណភាពនៃការបោះឆ្នោតនីមួយៗ បានកាត់បន្ថយភាពទោមនស្ស (និងអំពើហិង្សា) និងបានលើកកំពស់វប្បធម៌ថ្មីនៃលទ្ធិប្រជាធិបតេយ្យ និងការអភិវឌ្ឍន៍ដោយមានការចូលរួម ។ យន្តការខប់សែលនឹងអាចកសាងបន្ថែមទៀតដោយផ្អែកលើមូលដ្ឋានគ្រឹះនេះ ហើយផ្តល់ជាវេទិការយ៉ាងសំខាន់បែបនេះជាបន្តទៀតនៅក្នុងការជជែក និងការពិភាក្សាជាលក្ខណៈស្ថាបនា ។

ឯកឧត្តមបានលើកពីសារសំខាន់ពីយន្តការខប់សែលថា ជាវេទិកាសំរាប់ការបង្ការជំលោះនៅក្នុងការបោះឆ្នោតនៅកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៩៩ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើតអោយមានទីកន្លែងមិនសំអៀង សំរាប់អោយអង្គការសង្គមស៊ីវិល និងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិភាក្សាការងារទាក់ទងនឹងការបោះឆ្នោត និងបង្ការជំលោះ ។ ការជួបប្រជុំទាំងនេះ បានផ្ញើនសារៈប្រយោជន៍ជាបន្តបន្ទាប់ ហើយបានបន្តរហូតដល់ក្រោយពេលបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ២០០៣ ។ ការធ្វើអោយអ្នកពាក់ព័ន្ធផ្សេងៗបានជួបជុំគ្នា គឺជាជំហានយ៉ាងសំខាន់ និងមានលក្ខណៈជាវិជ្ជមាន ។

ជាទូទៅ យន្តការខប់សែល គឺជាវេទិកាអព្យាក្រឹត្យដែលមិនអាចខ្វះបានសំរាប់ការពិភាក្សាជាចំហរ រវាងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តំណាងរដ្ឋាភិបាល និងអ្នកមកពីសង្គមស៊ីវិលទាក់ទងនឹងសំណើនីតិវិធី និងការកែប្រែ និងព្រឹត្តិការណ៍បោះឆ្នោតផ្សេងទៀត ។ ការអភិវឌ្ឍន៍ដែលគួរអោយកត់សំគាល់មួយគឺថា នៅមុនការបោះឆ្នោតឆ្នាំ២០០៣ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បានចាប់ផ្តើមបង្ហាញសេចក្តីព្រាងបទបញ្ជារបស់ខ្លួនដល់ យន្តការខប់សែល ដើម្បីអោយមានការឆ្លើយតប ។ ជំហាននេះ បានលើកទឹកចិត្តអោយមានការយល់ដឹង និងការព្រមព្រៀងជារួមថែមទៀតអំពីតួនាទីការ និងទិសដៅនៃការបោះឆ្នោត និងលើកកំពស់គុណភាពបច្ចេកទេសនៃដំណើរការការបោះឆ្នោត ។ ផលប៉ះពាល់ជាបន្តបន្ទាប់ គឺការបង្ការជំលោះ និងការដោះស្រាយជំលោះ ។

ការប្រជុំទាំងនេះ ផ្តោតទៅលើអត្ថប្រយោជន៍រួមនៃការចូលរួមពេញលេញ តម្លាភាព និងកិច្ចសហការ ។ ការប្រជុំទាំងនេះ ក៏នឹងផ្តល់ផងដែរនូវការបង្ហាញយ៉ាងច្បាស់ថា ការបោះឆ្នោត និងលទ្ធិប្រជាធិបតេយ្យ មិនមែនជាការទទួលខុសត្រូវមួយគត់ ឬការទទួលខុសត្រូវដោយឡែករបស់ស្ថាប័នមួយដូចជា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឡើយ ទោះជាគណៈកម្មាធិការនេះអាចមានសមត្ថភាព និងប្រសិទ្ធភាពបែបណាក៏ដោយ ។ អង្គការសង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល គណបក្ស អ្នកផ្តល់ជំនួយរដ្ឋ និងបុគ្គលទាំងអស់ មានតួនាទី និងភារកិច្ចធានាអោយការបោះឆ្នោតទទួលបានជោគជ័យ និងថែរក្សាវប្បធម៌ប្រជាធិបតេយ្យ ។ មានទិសដៅជារួម និងតំលៃជាស្នូលមួយចំនួនដែលអាច និងត្រូវតែចែករំលែក និងគាំទ្រដោយប្រជាជនកម្ពុជាទាំងអស់ដោយមិនគិតពីការប្រកាន់គណបក្សនយោបាយ ។

ឯកឧត្តមសង្ឃឹមថា យន្តការខប់សែល នឹងដើរតួនាទីដ៏មានតំលៃសំរាប់ការពិភាក្សាជាចំហ រួមចំណែកចំពោះជោគជ័យនៃការបោះឆ្នោតចំនួនបីនៅពេលខាងមុខនេះ គឺការបោះឆ្នោតជ្រើសរើសសមាជិកព្រឹទ្ធសភា ដែលបានគ្រោងឡើងនៅឆ្នាំ២០០៦ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់នៅឆ្នាំ២០០៧ និងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រនៅឆ្នាំ២០០៨ ។

ទីបញ្ចប់ ឯកឧត្តម ក៏ដូចរាជរដ្ឋាភិបាលផងដែរបានថ្លែងអំណរសាទរ និងការគាំទ្រ នៅក្នុងការចាប់ផ្តើមជាផ្លូវការនៃយន្តការខប់សែល ដំណាក់កាលទី ២ នៅថ្ងៃនេះ ហើយបានប្រកាសបិទអង្គសន្និសីទប្រកបដោយមោទនភាព ។

មុនពេលបញ្ចប់អង្គសន្និសីទលោក **ឱក សេរី សោភក្តិ៍** បានថ្លែងអំណរគុណចំពោះឯកឧត្តម **ព្រុំ សុខា** ដែលបានផ្តល់នូវការគាំទ្រយ៉ាងខ្លាំងចំពោះយន្តការខប់សែលរយៈពេលបីឆ្នាំខាងមុខ ក្នុងនាមក្រសួងមហាផ្ទៃ ក៏ដូចជា រាជរដ្ឋាភិបាលកម្ពុជា ព្រមទាំងការផ្តល់ជាអនុសាសន៍ដ៏មានសារៈសំខាន់មួយចំនួនសំរាប់ ខប់សែល អនុវត្តនៅពេលខាងមុខ ។ លោកបានឆ្លៀតឱកាសនេះជំរាបដល់អង្គសន្និសីទ ពិសេសឯកឧត្តមអភិបាលខេត្ត អំពីផែនការបន្ត ដែលយន្តការខប់សែល នឹងចុះទៅតំបន់ទីមួយ គឺខេត្តតាកែវ កំពត ក្រុងព្រះសីហនុ និងកំពង់ស្ពឺ ដែលគ្រោងនឹងធ្វើនៅខែតុលា និងវិច្ឆិកា ២០០៥ ខាងមុខនេះ ដោយលោកស្នើសុំអោយមានការគាំទ្រចំពោះផែនការនេះ ។

អង្គសន្និសីទបានបញ្ចប់នៅម៉ោង ១២:៣០នាទី ថ្ងៃត្រង់ដោយទទួលបានលទ្ធផលជាវិជ្ជមាន ។

## កំណត់សំគាល់

* ខប់សែលជាអក្សរកាត់នៃពាក្យពេញថា *យន្តការបង្ការទំនាស់នៅក្នុងការបោះឆ្នោតនៅកម្ពុជា* ។ នេះជាយន្តការដ៏ពិសេសមួយដែលផ្តួចផ្តើមឡើងដោយ និងជារបស់កម្ពុជា ហើយគ្រប់គ្រងដំណើរការដោយវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៏កម្ពុជា ។ ខប់សែល ត្រូវបានបង្កើតឡើងនៅពាក់កណ្តាលឆ្នាំ១៩៩៩ ហើយបានផ្តល់នូវវេទិកាចំហ និងអព្យាក្រឹត្យ សំរាប់ការពិភាក្សាពីបញ្ហាផ្សេងៗទាក់ទិននឹងការបោះឆ្នោត ។ គោលដៅចំបងគឺដើម្បីបង្ការទំនាស់ អំពើហិង្សា និងការយល់ច្រឡំពីគ្នាក្នុងដំណើរការបោះឆ្នោត ដោយធ្វើការកសាងទំនុកចិត្ត និងលើកស្ទួយវប្បធម៌នៃការពិភាក្សាគ្នា ។ យន្តការនេះ គឺជាភស្តុតាងជាក់ស្តែងមួយដ៏សំខាន់នៃការប្តេជ្ញាចិត្តរបស់ CDRI ក្នុងការធ្វើការងារជាដៃគូជាមួយស្ថាប័ន និងអង្គការកម្ពុជាឯទៀតៗ ដើម្បីពង្រឹងរបបគ្រប់គ្រងប្រជាធិបតេយ្យនៅកម្ពុជា ។

ខប់សែល-ដំណាក់កាលទី១ ដែលចាប់ផ្តើមពីខែសីហា ១៩៩៩ ដល់កញ្ញា ២០០៣ បានធ្វើការពិភាក្សាពីបញ្ហាបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០០២ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៣ ដោយបានជួបប្រជុំប្រចាំខែ ៥០ដង និងមានការចូលរួមពីតំណាងជាង ១០០នាក់ មកពីគ្រប់ស្ថាប័ន និងអង្គការដែលពាក់ព័ន្ធនឹងការបោះឆ្នោត ។

ខប់សែល-ដំណាក់កាលទី២ ដែលចាប់ផ្តើមនៅខែមិថុនា ២០០៥ នឹងធ្វើការពិភាក្សាលើបញ្ហានៃការបោះឆ្នោតព្រឹទ្ធសភាឆ្នាំ២០០៦ ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំ២០០៧ និងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រឆ្នាំ២០០៨ ។ ដោយមានជំនួយហិរញ្ញវត្ថុពីកម្មវិធីអភិវឌ្ឍន៏សហប្រជាជាតិ (UNDP) ខប់សែល ដំណាក់កាលទី២ នឹងដំណើរការរយៈពេល ៣ឆ្នាំ តាមរយៈរចនាសម្ព័ន្ធចំនួន ៦ រួមមានសន្និសីទថ្នាក់ជាតិបើក យន្តការខប់សែលប្រជុំស្នូល ខប់សែលប្រជុំទូលាយ ខប់សែលប្រជុំថ្នាក់ខេត្ត ខប់សែលតាមរយៈប្រព័ន្ធផ្សព្វផ្សាយ និងសន្និសីទថ្នាក់ជាតិបិទយន្តការ ។

ខប់សែល ដំណាក់កាលទី ២ នេះចាប់ផ្តើមដោយការរៀបចំសន្និសីទថ្នាក់ជាតិនេះ ក្នុងគោលបំណងប្រកាសជាផ្លូវការនូវការចាប់ផ្តើមយន្តការ ខប់សែល ដំណាក់កាលទី ២ និងជាការជំរាបជូនជាពត៌មានដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់អោយត្រៀមខ្លួនសំរាប់ចូលរួមក្នុងដំណើរការនេះ ។